# គាថាធម្មបទ បាលី.ប្រែ

## ពន្យល់វេយ្យាករណ៍


បណ្ឌិតមហា សេក-កាឡូ អតីតនិស្សិត

សាលាបាលីជាន់ខ្ពស់ គ្រូបង្ហាត់ក្នុងក្រសួងសិក្សាធិការជាតិ

រៀបរៀង

ព្រះទេពសត្ថា កិម-តូ ពិនិត្យសម្រេច


**ចប្ចងហោយ**


ផ្ទះលេខ១៣៦អឺ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស ២៤៩៧ គ.ស ១៩៥៤

# គាថាធម្មបទ ឆ្លាសី.ប្រែ

# ពន្យល់វេយ្យាករណ៍


បណ្ឌិតមហា សេក-កាឡ អតីតនិស្សិត

សាលាបាលីជាន់ខ្ពស់ គ្រូបង្ហាត់ក្នុងក្រសួងសិក្សាធិការជាតិ

រៀបរៀង

ព្រះទេពសត្ថា កិម-តូ ពិនិត្យសម្រេច





ការផ្សាយរបស់

បណ្ណាគារ សុមនសុវណ្ណី លេខ ១៩៥

វិថីហង់រី-រុស្សិយេរ

ក្រុងភ្នំពេញ

រក្សាសិទ្ធិ

ព.ស. ២.៤៩៧ = គ.ស. ១.៩៥៤

# អារម្ភកថា

កាលខ្ញុំនៅជានិស្សិតថ្នាក់ឆ្នាំទី ៤ នៃសាលាបាលីជាន់ខ្ពស់ពីឆ្នាំ ១៩៥២-៥៣ បានឆ្លៀតឱកាសទំនេរ បង្រៀនវេយ្យាករណ៍ ដែលមានក្នុងផ្ទៃគាថាធម្មបទ ដល់ភិក្ខុសាមណេរជាបេក្ខសមណៈបម្រុងប្រឡងចូលសាលាបាលីជាន់ខ្ពស់ ; ការបង្រៀននោះបានជួបប្រទះលើសេចក្ដីលំបាកជាច្រើន ព្រោះពុំមានក្បួនច្បាប់បែបផែនសម្រាប់បង្រៀនសោះ ម្ល៉ោះហើយចេះតែកាត់គម្ពីរសៀវភៅនេះខ្លះនោះខ្លះមកបង្រៀន ៗ តាំងពីពេលនោះមក ខ្ញុំបានប្រតិស្ឋានចិត្តថា "នឹងបង្កើតសៀវភៅក្បួនច្បាប់នេះឲ្យមានឡើង ដើម្បីស្រួលដល់ការសិក្សាភាសាបាលី" ។ លុះដល់ខ្ញុំបានប្រឡងចេញពីសាលាបាលីជាន់ខ្ពស់ពី ឆ្នាំ១៩៥៣ បានទទួលនិមន្តទៅបង្ហាត់នៅសាលាបាលីវត្តព្រះពុទ្ធមានបុណ្យ សង្កាត់លេខ ៣ ក្រុងភ្នំពេញ ជាឱកាសបើកផ្លូវបំណងរបស់ខ្ញុំដែលដក់ទុកមកយូរ ហើយឲ្យក្ដីស្មាន់ចំពោះការធ្វើសៀវភៅនេះ ។ នៅវេលានោះខ្ញុំតាំងវិរិយភាពយ៉ាងម៉ឺងម៉ាត់ បានយកសៀវភៅអធិប្បាយគាថាធម្មបទរបស់លោកគ្រូអាចារ្យឈឹម - ស៊ុម ១ បទានុក្រមធម្មបទរបស់ព្រះតេជព្រះគុណទេពសត្ថា គិម - តូរ ១ បទានុក្រមរបស់ព្រះតេជព្រះគុណព្រះឧបាលីវង្ស ប៊ុន - សែស ១ អភិធានប្បទីបិកាសូចិ (អក្សរសៀម) ១ កច្ចាយនរូបត្ថមកភាគទី ១ ភាគទី ២ របស់សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយក គណៈមហានិកាយ (ជួន - ណាត) ១ (ផ្សំទ្រឹស្ដីរបស់ខ្លួនខ្ញុំបន្តិចបន្តួច) មកស្រង់

ប្រមូលរៀបរៀងឲ្យកើតជាសៀវភៅ  រៀង ៗ  កំពុងធ្វើសៀវភៅនេះ ខ្ញុំបាទមហាឧត្តមវិជ្ជា ច្រឹក-ជឹម ជា  ប្រិយមិត្រនៅបង្រៀនសាលាបាលីរងវត្តព្រះពុទ្ធមានបុណ្យជាមួយគ្នា  ពិគ្រោះប្រឹក្សាការខុសត្រូវផង ខ្ញុំមានសេចក្ដីអរគុណចំពោះមហាប្រិ  ត្រនេះជាកិរិយាភាព ៗ លុះធ្វើចប់ពីយមកវត្តផលបណ្ឌិតវត្ត  ខ្ញុំបាទយកទៅជូនព្រះតេជព្រះគុណឈឹម-ប៊ុម ជាសាស្ត្រាចារ្យសា  ាលីជាន់ខ្ពស់ជួយផ្ទៀងផ្ទាត់ ជូនជាលោកមានកិច្ចមមាញឹកពេក  កក៏យកទៅប្រគេនព្រះតេជព្រះគុណព្រះទេពសត្ថា គិម-តូរ ឲ្យជួយ  ស្រៀកែសម្រួល ៗ ព្រះតេជព្រះគុណអង្គនេះយកព្រះទ័យទុកដាក់ជួយពិ  កែសម្រួលដរាបដល់ចប់  ព្រមទាំងពិនិត្យកែសម្រួលវិញ្ញាបោះពុម្ព  ទៀត  ធ្វើឲ្យខ្ញុំមានសេចក្ដីសង្ឃឹមថាបានត្រឹមត្រូវហ្មត់ចត់ល្អ  ព្រោះលោកមានអត្ថកោសល្យបរិបូណ៌ក្នុងវេយ្យាករណ៍បាលី ៗ ខ្ញុំមានសេចក្ដីអរគុណចំពោះព្រះតេជព្រះគុណអង្គនេះជាក្រៃលែង ៗ

ទីបំផុតនេះ ខ្ញុំសូមឧទ្ទិសផលកុសលដែលបណ្ដាលចេញពីការរៀបរៀងសៀវភៅនេះ បូជាចំពោះ បុព្វការីមានមាតាបិតាឧបជ្ឈាចារ្យជាដើម ដែលបានចិញ្ចឹមបីបាច់រក្សាបង្ហាត់បង្រៀនខ្ញុំ ឲ្យបានល្អគលាស់បានចេះដឹងធុះយល់សេចក្ដីគាចស្លាបនាសៀវភៅនេះឡើងបាន សូមឲ្យលោកទាំងនោះ បានទទួលនូវផលមនុញ្ញផលនៃធម្មទាននេះ ឲ្យបានសេចក្ដីសុខចំរើនអស់កាលជាអង្វែងទៅ ៗ

ភាគផលកុសលទីពីរ សូមឧទ្ទិសជារាជពលីធម្មបណ្ណាការថ្វាយព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន ជាព្រះប្រិយមហាក្សត្រនៃកម្ពុជនាបច្ចុប្បន្នកាលនេះ សូមទ្រង់ឋិតនៅក្នុងសិរីរាជសម្បត្តិ សម្រេចព្រះរាជករណីយកិច្ចគ្រប់ប្រការ សមតាមព្រះរាជបណិធិកុំបីឃ្លៀងឃ្លាតឡើយ ។

សូមផ្ញើជំនឿ ចំពោះវេយ្យាករណបណ្ឌិតបច្ចុប្បន្ន នឹងអនាគតក្រែងការតាំងឈ្មោះហ្នឹងពុំត្រឹមត្រូវចំពោះបទណាមួយ ដែលមានក្នុងសៀវភៅនេះ, សូមមេត្តាជួយកែតម្រូវផង ដើម្បីជាអាយុរបស់ព្រះពុទ្ធសាសនាតទៅ ។

បណ្ឌិតមហា សេក-កាឡូ

គ្រូបង្ហាត់ក្នុងក្រសួងសិក្សាធិការជាតិ

ភ្នំពេញ, ថ្ងៃទី ១ មករា ២៤៩៦ / ១៩៥៤

## សារបញ

### យមកវគ្គ ទី ១

មាតិកានុក្រម ទំព័រ


១– ចក្ខុបាលត្ថេរវត្ថុ ( មនោបុព្វង្គមា )........១

២– មដ្ឋកុណ្ឌលិវត្ថុ ( មនោបុព្វង្គមា )........៣

៣– តិស្សត្ថេរវត្ថុ ( អក្កោច្ឆិ មំ)..............៤

៤– កាឡយក្ខិនិយា ឧប្បត្តិវត្ថុ ( ន ហិ វេរេន )........៦

៥– កោសម្ពិកវត្ថុ ( បរេ ច ន វិជានន្តិ )....៧

៦– ចុល្លកាឡមហាកាឡវត្ថុ ( សុភានុបស្សឹ )........៨

៧– ទេវទត្តវត្ថុ ( អនិក្កសាវោ )........១៣

៨– សញ្ជយស្សាគមនវត្ថុ ( អសារេ សារមតិនោ ).១៥

៩– នន្ទត្ថេរវត្ថុ ( យថា អគារំ )........១៧

១០– ចុន្ទសូករិកវត្ថុ ( ឥធ សោចតិ )........១៩

១១– ធម្មិកឧបាសកវត្ថុ ( ឥធ មោទតិ )........២០

១២– ទេវទត្តវត្ថុ ( ឥធ តប្បតិ )..........២១

១៣– សុមនទេវីវត្ថុ ( ឥធ នន្ទតិ )........២៣

១៤– ទ្វេសហាយកភិក្ខុវត្ថុ ( ពហុម្បិ ចេ)........២៣


### អប្បមាទវគ្គ ទី ២


១– សាមាវតីវត្ថុ ( អប្បមាទោ )..........២៧

២– កុម្ភឃោសកវត្ថុ ( ឧដ្ឋានវតោ )........៣១

## សារបញ


| មាតិកានុក្រម | | ទំព័រ |
|---|---|---|
| ៣– ចូឡបន្ថកត្ថេរវត្ថុ | ( ឧដ្ឋានេនប្បមាទេន ) | ៣៣ |
| ៤– ពាលនក្ខត្តវត្ថុ | ( បមាទមនុយុញ្ជន្តិ )..... | ៣៤ |
| ៥– មហាកស្សបត្ថេរវត្ថុ | ( បមាទំ អប្បមាទេន ).. | ៣៧ |
| ៦– ទ្វេសហាយកភិក្ខុវត្ថុ | ( អប្បមត្តោ បមត្តេសុ ).. | ៣៩ |
| ៧– សក្កវត្ថុ | ( អប្បមាទេន មឃវា )... | ៤០ |
| ៨– អញ្ញតរភិក្ខុវត្ថុ | ( អប្បមាទរតោ ភិក្ខុ )... | ៤១ |
| ៩– និគមវាសិតិស្សត្ថេរវត្ថុ | ( អប្បមាទរតោ ភិក្ខុ )... | ៤៣ |
| **ចិត្តវគ្គ ទី ៣** | | |
| ១– មេឃិយត្ថេរវត្ថុ | ( ផន្ទនំ ចបលំ ចិត្តំ )..... | ៤៤ |
| ២– អញ្ញតរភិក្ខុវត្ថុ | ( ទុន្និគ្គហស្ស លហុនោ ). | ៤៧ |
| ៣– ឧក្កណ្ឋិតភិក្ខុវត្ថុ | ( សុទុទ្ទសំ សុនិបុណំ ). | ៤៨ |
| ៤– ភាគិនេយ្យសង្ឃរក្ខិតត្ថេរវត្ថុ | ( ទូរង្គមំ ឯកចរំ )...... | ៤៩ |
| ៥– ចិត្តហត្ថត្ថេរវត្ថុ | ( អនវដ្ឋិតចិត្តស្ស )..... | ៥០ |
| ៦– អារទ្ធវិបស្សកភិក្ខុវត្ថុ | ( កុម្ភូបមំ កាយមិមំ )... | ៥៣ |
| ៧– បូតិគត្តតិស្សត្ថេរវត្ថុ | ( អចិរំ វតយំ កាយោ )... | ៥៦ |
| ៨– នន្ទគោបាលកវត្ថុ | ( ទិសោ ទិសំ យន្តំ )... | ៥៨ |
| ៩– សោរេយ្យត្ថេរវត្ថុ | ( ន តំ មាតា បិតា )... | ៥៩ |

# សារបញ

មាតិកានុក្រម ទំព័រ

## -បុប្ផវគ្គទី ៤-


១- បឋវីកថាបសុតភិក្ខុវត្ថុ (គោ ឥមំ បឋវី)..........៦១

២- មរីចិកម្មដ្ឋានិកត្ថេរវត្ថុ (ផេណូបមំ កាយមិមំ).......៦៣

៣- វិឌូឌភវត្ថុ (បុប្ផានិ ហេវ បចិនន្តំ).......៦៥

៤- បតិបូជិកាវត្ថុ (បុប្ផានិ ហេវ បចិនន្តំ).......៦៦

៥- មច្ឆរិយកោសិយវត្ថុ (យថាបិ ភមរោ បុប្ផំ).......៦៧

៦- បាដិកាជីវកវត្ថុ (ន បរេសំ វិលោមានិ).....៦៨

៧- ឆត្តបាណិឧបាសកវត្ថុ (យថាបិ រុចិរំ បុប្ផំ)........៦៩

៨- វិសាខាវត្ថុ (យថាបិ បុប្ផរាសិម្ហា)........៧១

៩- អានន្ទត្ថេរបញ្ហាវត្ថុ (ន បុប្ផគន្ធោ)...........៧២

១០- មហាកស្សបត្ថេរបិណ្ឌបាតទានវត្ថុ (អប្បមត្តោ អយំ).......៧៥

១១- គោធិកត្ថេរបរិនិព្វានវត្ថុ (តេសំ សម្បន្នសីលានំ)......៧៥

១២- គរហទិន្នវត្ថុ (យថា សង្ការធានស្មឹ).....៧៧


## ពាលវគ្គទី ៥


១- អញ្ញតរបុរិសវត្ថុ (ទីឃា ជាគរតោ រត្តិ).....៨០

២- មហាកស្សបត្ថេរសទ្ធិវិហារិកវត្ថុ (ចរញ្ចេ នាធិគច្ឆេយ្យ)...៨១

៣- អានន្ទសេដ្ឋិវត្ថុ (បុត្តា មត្ថិ ធនមត្ថិ).....៨៣

# សារបាញ

មាតិកានុក្រម — ទំព័រ

## ពាលវគ្គ ទី ៥


៤– គណ្ឋិភេទកចោរវត្ថុ (យោ ពាលោ)............៨៤

៥– ឧទាយិត្ថេរវត្ថុ (យាវជីវម្បិ ចេ)..........៨៥

៦– បាវេយ្យកភិក្ខុវត្ថុ (មុហុត្តមបិ ចេ វិញ្ញូ).......៨៦

៧– សុប្បពុទ្ធកុដ្ឋិវត្ថុ (ចរន្តិ ពាលា ទុម្មេធា)......៨៧

៨– កស្សកវត្ថុ (ន តំ កម្មំ កតំ សាធុ)...៨៨

៩– សុមនមាលាការវត្ថុ (តញ្ច កម្មំ កតំ សាធុ)... ៨៩

១០– ឧប្បលវណ្ណាវត្ថុ (មធុវា មញ្ញតិ ពាលោ)...៩០

១១– ជម្ពុកាជីវកវត្ថុ (មាសេ មាសេ កុសគ្គេន).៩១

១២– អហិប្រេតវត្ថុ (ន ហិ បាបំ កតំ កម្មំ)...៩៣

១៣– សដ្ឋិកូដប្រេតវត្ថុ (យាវទេវ អនត្ថាយ)...... ៩៥

១៤– សុធម្មត្ថេរវត្ថុ (អសន្តំ ភាវនមិច្ឆេយ្យ).....៩៦

១៥– វនវាសិតិស្សត្ថេរវត្ថុ (អញ្ញា ហិ លាភូបនិសា)...៩៩


## បណ្ឌិតវគ្គ ទី ៦


១– រាធត្ថេរវត្ថុ (និធីនំវ បវត្តារំ)........១០១

២– អស្សជិបុនព្វសុកភិក្ខុវត្ថុ (ឱវទេយ្យានុសាសេយ្យ)...១០៣

៣– ឆន្នត្ថេរវត្ថុ (ន ភជេ បាបកេ មិត្តេ).១០៥

# សារបញ


មាតិកានុក្រម ទំព័រ

## បណ្ឌិតវគ្គទី ៦

៤– មហាកប្បិនត្ថេរវត្ថុ (ធម្មបីតិ សុខំ សេតិ)......១០៦

៥– បណ្ឌិតសាមណេរវត្ថុ (ឧទកំ ហិ នយន្តិ នេត្តិកា)..១០៧

៦– លកុណ្ឌកភទ្ទិយត្ថេរវត្ថុ (សេលោ យថា ឯកឃនោ)..១០៨

៧– កាណមាតាវត្ថុ (យថាបិ រហទោ គម្ភីរោ).....១០៩

៨– បញ្ចសតភិក្ខុវត្ថុ (សព្វត្ថ វេ សប្បុរិសា វជន្តិ)...១១០

៩– ធម្មិកត្ថេរវត្ថុ (ន អត្តហេតុ ន បរស្ស ហេតុ)១១២

១០– ធម្មស្សវនវត្ថុ (អប្បកា តេ មនុស្សេសុ)....១១៣

១១– អាគន្តុកភិក្ខុវត្ថុ (កណ្ហំ ធម្មំ វិប្បហាយ)......១១៦

# អក្សរសង្ខេប
## សម្រាប់ប្រើក្នុងសៀវភៅនេះ

| | |
|---|---|
| គុ. | = គុណនាមជាត្រៃលិង្គ |
| បុំ. | = បុំលិង្គ |
| នបុំ. | = នបុំសកលិង្គ |
| ឥ. | = ឥត្ថីលិង្គ |
| កិ. | = កិរិយាសព្ទអាខ្យាត |
| អ.ស. | = អព្យយសព្ទនាម |
| អ. | = អព្យយកិរិយា |
| អ.ន. | = អព្យយនាម |
| ទុតិ. ពហុព្វី. | = ទុតិយាពហុព្វីហិសមាស |
| តតិ. ពហុព្វី. | = តតិយាពហុព្វីហិសមាស |
| ចតុ. ពហុព្វី. | = ចតុត្ថីពហុព្វីហិសមាស |
| បញ្ច. ពហុព្វី. | = បញ្ចមីពហុព្វីហិសមាស |
| ឆ. ពហុព្វី. | = ឆដ្ឋីពហុព្វីហិសមាស |
| ស. ពហុព្វី. | = សត្តមីពហុព្វីហិសមាស |
| កា.កា. | = កត្តុរូបកត្តុសាធនៈ |
| កម្ម. កម្ម. | = កម្មរូបកម្មសាធនៈ |

ភ.ភ. = ភាវរូបភាវសាធនៈ

ក.ត. = កត្តុរូបកេវលសាធនៈ

ស.ត. = សមាសរូបកេវលសាធនៈ

បុំ.នបុំ. = បុំលិង្គនិងនបុំសកលិង្គ

ក.អធិ. = កត្តុរូបអធិករណសាធនៈ

កម្ម.អធិ. = កម្មរូបអធិករណសាធនៈ

ក.ករ. = កត្តុរូបករណសាធនៈ

កម្ម.ករ. = កម្មរូបករណសាធនៈ

ក.សម្ប. = កត្តុរូបសម្បទានសាធនៈ

កម្ម.សម្ប. = កម្មរូបសម្បទានសាធនៈ

ទុតិ.តប្បុ. = ទុតិយាតប្បុរិសៈ

តតិ.តប្បុ. = តតិយាតប្បុរិសៈ

ចតុ.តប្បុ. = ចតុត្ថីតប្បុរិសៈ

បញ្ច.តប្បុ. = បញ្ចមីតប្បុរិសៈ

ឆ.តប្បុ. = ឆដ្ឋីតប្បុរិសៈ

ស.តប្បុ. = សត្តមីតប្បុរិសៈ

ទុក.តប្បុ. = ទុកយតប្បុរិសៈ

វិ. = វិគ្គហៈ

ន.បុ.ឆ.ពហុព្វី. = នបុព្វបទឆដ្ឋីពហុព្វីហិសមាស

| | |
|---|---|
| វិ.បុ. | = វិសេសនបុព្វបទសមាស |
| វិ.ឧ. | = វិសេសនុត្តរបទសមាស |
| សក. | = សកត្ថប្បច្ច័យ |
| ក.កម្ម. | = កត្តុរូបកម្មសាធន |
| ក.អបាទា. | = កត្តុរូបអបាទានសាធនៈ |
| ទុតិ.ឆ.ពហុព្វី. | = ទុតិយាឆដ្ឋីភិន្នាធិករណពហុព្វីហិសមាស |
| តតិ.ភិន្នា.ឆ.ពហុព្វី. | = តតិយាឆដ្ឋីភិន្នាធិករណពហុព្វីហិសមាស |
| សត្ត.ភិន្នា.ឆ.ពហុព្វី. | = សត្តមីភិន្នាធិករណពហុព្វីហិសមាស |

## គាថាធម្មបទបាលី-ប្រែ

## ពន្យល់វេយ្យាករណ៍

### យមកវគ្គទី ១

### ១– ចក្ខុបាលត្ថេរវត្ថុ

មនោបុព្វង្គមា ធម្មា    មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន    ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ    ចក្កំវ វហតោ បទំ ។

*(ប្រែ) ធម៌ទាំងឡាយ មានចិត្តដល់មុន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត, បើបុគ្គលមានចិត្តដែលទោសប្រទូស្ត ហើយ ពោលក្តី ធ្វើក្តី, សេចក្តីទុក្ខតែងជាប់តាមនូវបុគ្គលនោះ ព្រោះការពោល និងការធ្វើនោះ ដូចជាកង់រទេះជាប់តាមស្នាមជើងគោដែលកំពុងនាំទៅ (នូវនឹម) ។*

*ពន្យល់វេយ្យាករណ៍*

មនោបុព្វង្គម    គុ. (មន + បុព្វង្គម) "មានចិត្តដល់មុន, មានចិត្តជាប្រធាន" វិ. មនោ បុព្វង្គមោ យេសំ តេ > មនោបុព្វង្គមា (ធម្មា) ធ. ពហុ. ។ បុព្វង្គម < បុព្វ + គម + ក្វិ, "(ចិត្ត) ដល់មុន" វិ. បុព្វំ បុព្វេ វា គច្ឆតីតិ > បុព្វង្គមោ (មនោ) ក.ក. ។

ធម្ម បុំ. (ធរ + ម្ម) "(សភាវ) ទ្រទ្រង់ = (ធម៌)" វិ. ធារេតីតិ > ធម្មោ (សភាវោ); ក.ក. ។

មនោសេដ្ឋ គុ. (មន + សេដ្ឋ) "មានចិត្តប្រសើរដោយវិសេស, មានចិត្តធំ" វិ. មនោ សេដ្ឋោ យេសំ តេ > មនោសេដ្ឋា (ធម្មា) ឆ. ពហុព្វី. ។

មនោមយ គុ. (មន + មយ) "សម្រេចហើយដោយចិត្ត" វិ. មនសា និព្វត្តា > មនោមយា (ធម្មា); និប្ផន្ន-តទ្ធិត ឬ បកតិតទ្ធិត ។

បទុដ្ឋ គុ. (ប + ទុស + ត) "ដែល...ប្រទូស្តហើយ" ។

ភាសតិ កិ. (ភាស + អ + តិ - វ.) "ពោល, ..." ។

ករោតិ កិ. (ករ + ឱ + តិ - វ.) "ធ្វើ" ។

តតោ អ. សព្វ. (ត + តោ) "អំពី...នោះ" ។

ទុក្ខមន្វេតិ សន្ធិ. (ទុក្ខំ + អន្វេតិ) មិត្តហិតាទេសសន្ធិ ។ ទុក្ខ នបុំ. < ទុ + ខម + ក្វ. "ផលផ្តាត ដែលគេអត់ទ្រាំបានដោយកម្រ (សេចក្តីទុក្ខ)" វិ. ទុ:ខេន ខមិយតីតិ > ទុក្ខំ (ធម្មជាតំ) កម្ម. កម្ម. ។

អន្វេតិ កិ. (អនុ + ឥ + អ + តិ - វ.) "តែងដល់តាម, ទៅតាម, តាមទៅ, អន្ទោលតាម" ។

ចក្កំវ  សន្ធិ. ( ចក្កំ + ឥវ ) បរស្សរលោបសន្ធិ ។ ចក្ក < គមន + ករ + ក្វិ, "(វត្ថុ) ជាគ្រឿងធ្វើនូវដំណើរ = ( ចក្រ, កង់ )  វិ. ចក្កោតិ គមនំ ករោតីតិ > ចក្កំ (វត្ថុ) ក. ករ. ។

វហតោ  គុ. ( វហន្ត + ស - ឆដ្ឋីវិ. ន្ត + ស > តោ ) " កាលនាំទៅ " វហន្ត < វហ + អន្ត ។

បទំ  បុំ., នបុំ. (បទ + អំ) "(អវយវៈ) ជាគ្រឿងដែលដើរទៅ" (ជើង) វិ. បជ្ជតេ គច្ឆតេ ឯតេនាតិ > បទំ (អវយវៈ) កម្ម. ករ. ។

## ២- មដ្ឋកុណ្ឌលិវត្ថុ

មនោបុព្វង្គមា ធម្មា  មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន  ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ  ឆាយាវ អនុបាយិនី ។

*(ប្រែ) ធម៌ទាំងឡាយ មានចិត្តដល់មុន មានចិត្តប្រសើរដោយវិសេស សម្រេចហើយដោយចិត្ត, បើបុគ្គលមានចិត្តជ្រះថ្លាហើយ ពោលក្តី ធ្វើក្តី, សេចក្តីសុខតែងជាប់តាមនូវបុគ្គលនោះ ព្រោះការពោល និងការធ្វើនោះ ដូចជាស្រមោលដែលទៅតាមជាប្រក្រតី ។*

### ពន្យល់វេយ្យាករណ៍

មនោបុព្វង្គម, ធម្ម, មនោសេដ្ឋ, មនោមយ,

ភាសតិ, ភាវេតិ, ភវតោ, អវេក្ខតិ; ចូរមើលរឿងចក្ខុបាលលេខ ១ ក្នុងយមកវគ្គទី ១ ។

បសន្ន គុ. (ប+សទ+ត) "ជ្រះថ្លាហើយ, ថ្លា" ។

អនុយាយិនី គុ. (អនុ+យា+ណី ឬ អយ+ណី+ឥនី) "ទៅតាម, ប្រព្រឹត្តទៅតាម, មានក. ទៅតាមជាប្រក្រតី, មានក. អន្ទោលទៅតាមជាប្រក្រតី" វិ. អនុយាយិនំ សីលមស្សាតិ > អនុយាយិនី (ឆាយា) ស. ត. ។

ឆាយាវ សន្ធិ. (ឆាយា+ឥវ) បរសរលោបសន្ធិ ។ ឆាយា ឥ. < ឆា+យ+អាឥ. "(ធម្មជាតិ) កាត់ខ្វាសេចក្តីសង្ស័យ = (ស្រមោល, ម្លប់)" វិ. ឆេតិ ឆិន្ទតិ សំសយំ ឆាតិ > ឆាយា (ធម្មជាតិ) ក. ក. ។

សុខ នបុំ. (សុ+ខម+ក្វ.) (ធម្មជាត) "ដែលគេអត់ទ្រាំបាន ដោយងាយ = (សេចក្តីសុខ)" វិ. សុខេន ខមិយតីតិ > សុខំ (ធម្មជាតំ) កម្ម. កម្ម. ។

### ៣ - តិស្សត្ថេរវត្ថុ

អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ
អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នូបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

(ប្រែ) ជនទាំងឡាយឯណា ចងពៀរនោះថា "ជនឯណោះបានជេរអញ, ជនឯណោះបានប្រហារអញ, ជនឯណោះបានផ្ចាញ់អញ, ជនឯណោះបានលួចយកទ្រព្យអញ" ដូច្នេះ, ពៀររបស់ជនទាំងឡាយនោះមិនរម្ងាប់ទេ; លុះតែជនទាំងឡាយឯណា មិនបានចងពៀរថា "ជនឯណោះបានជេរអញ, ជនឯណោះបានប្រហារអញ, ជនឯណោះបានផ្ចាញ់អញ, ជនឯណោះបានលួចទ្រព្យអញ" ដូច្នេះ, ទើបពៀររបស់ជនទាំងឡាយនោះរម្ងាប់បាន ។

## ពន្យល់វេយ្យាករណ៍

អក្កោច្ឆិ កិ. ( អ+កុធ+អ+ត្ត)-អជ្ជ. ) "បានជេរហើយ" ។

អវធិ កិ. ( អ+ហន, ហន>វធ+អ+ត្ត)-អជ្ជ. ) "បានប្រហារហើយ, បានសម្លាប់ហើយ, បានវាយហើយ" ។

អជិនិ កិ. (អ+ជិ+នា+ត្ត)-អជ្ជ.) "បានផ្ចាញ់ហើយ. បានឈ្នះហើយ" ។

អហាសិ កិ. ( អ+ហរ+អ+ត្ត)-អជ្ជ.+ស-អា. ) បាននាំទៅហើយ, បានលួចហើយ" ។

ឧបនយ្ហន្តិ កិ. (ឧប+នហ+យ+អន្តិ-វ.) "ចូលទៅចង,ចងមាំ,ចងទុក" ។

វេរ នបុំ. (វិរូប+អរ+អ) "(ទោសជាត) ទៅដោយរូបវិបុក = (ពៀរ)" វិ. វិរុទ្ធេន អរតិ គច្ឆតីតិ>វេរំ (ទោសជាតំ) ក. ក. ។

សម្មតិ កិ. ( សម+យ+តិ-វ.) "ស្ងប់, រម្ងាប់" ។

ឧបសម្មតិ ក. (ឧប+សមុ+យ+តិ-វ.) "ស្ងប់, ចូលទៅរម្ងាប់" ។

តេសូបសម្មតិ សន្ធិ. (តេសំ+ឧបសម្មតិ) និគ្គហិតលោបសន្ធិនិងបរទីឃ-
សន្ធិ ។

នូបសម្មន្តិ សន្ធិ. (ន+ឧបសម្មន្តិ) បរទីឃសន្ធិ ។

## ៤- កាឡីយក្ខិនិយា វត្ថុ

ន ហិ វេរេន វេរានិ សម្មន្តីធ កុទាចនំ
អវេរេន ច សម្មន្តិ ឯស ធម្មោ សនន្តនោ

(ប្រែ) ពៀរទាំងឡាយក្នុងលោកនេះ មិនដែលរម្ងាប់ដោយពៀរក្នុងកាលណាមួយទេ, ពៀរទាំងឡាយរម្ងាប់បានដោយសារតែមិនមានពៀរប៉ុណ្ណោះឯង; ធម៌នេះជាបវេណីរបស់អ្នកប្រាជ្ញពីបុរាណ ។

### ពន្យល់វេយ្យាករណ៍

វេរ, សម្មន្តិ, ធម្ម ចូលមើលរឿងតិស្សត្ថេរលេខ ៣ ក្នុងយមកវគ្គទី ១ ។

សម្មន្តីធ សន្ធិ. (សម្មន្តិ+ឥធ) បុព្វសរលោបសន្ធិនិងបរទីឃសន្ធិ ។

កុទាចនំ អ. សព្វ. (កុ+ទាចនំ) "ក្នុងកាលណា" វិ. កស្មឹ
កាលេ ឥតិ កុទាចនំ ។

អវេរ គុ. (ន+វេរ) "មានៈពៀរមិនមាន" វិ. នត្ថិ វេរំ
អស្សាតិ > អវេរោ (ជនោ), ឧបុ. ឆ.ពហុព្វី. ។

“កិ. មិនមាននៃទៀត” វិ. បរស្ស អភាវោ > អបរំ;
អព្យយីភាវសមាស ។

ឯស   សន្ធិ. ( ឯសោ ) សាគមសន្ធិ ។

សនន្តន   គុ. (សនំ+តន) “មានក្នុងបុរាណកាល, មានក្នុងកាលមុន” វិ. សនំ បុរាណេ ភវោ > សនន្តនោ (ធម្មោ) ករតទ្ធិត ។

## ៤– កោសម្ពិកវត្ថុ

បរេ ច ន វិជានន្តិ មយមេត្ថ យមាមសេ
យេ ច តត្ថ វិជានន្តិ តតោ សម្មន្តិ មេធគា ។

(ប្រែ) ជនទាំងឡាយដទៃ (ពីបណ្ឌិត) មិនដឹងច្បាស់ថា “យើងទាំងឡាយលំបាកក្នុងកណ្តាលប្រជុំជននេះដោយពិត” ឯជនទាំងឡាយដែលជាបណ្ឌិតទើបដឹងច្បាស់ក្នុងហេតុនោះ; កលហធម៌ជាគ្រឿងប្រកួតប្រកាន់ទាំងឡាយ រមែងរម្ងាប់អំពីបណ្ឌិតទាំងឡាយនោះ ។

### ពន្យល់វេយ្យាករណ៍

វិជានន្តិ   កិ. (វិ+ញា, ញា>ជា+នា+អន្តិ-វ.) “ដឹងច្បាស់, ដឹងប្រាកដ” ។

មយមេត្ថ   សន្ធិ. (មយំ+ឯត្ថ) ទិគ្ឃាទិកាទេសសន្ធិ ។ ឯត្ថ<ឯត ឬ ឥម+ត្ថ “ក្នុង... នុ៎ះ, ក្នុង... នេះ” ។

យមាម   កិ. ( យម+អ+ម-វ. ) “លំបាក, ទឹងលំបាក” ។

តត្ថ   អ. សព្វ. ( ត+ត្ថ. ) “ក្នុង... នោះ” ។

តតោ សម្មត្តិ ចូរមើលរឿងកាឡីយក្ខិនីលេខ ៤ ក្នុងយមកវគ្គទី ១ ។

មេធគ   បុ. (មេធ+គម+ក) “(ពោស) បៀតបៀនទូវនិស្ស័យ

របស់ខ្លួនដងនូវបុគ្គលដទៃផង រមែងទៅ=(ជម្លោះ)”

វិ. អត្តនោ និស្សយញ្ច បរញ្ច មេធមានោ

គច្ឆតិ, តិ > មេធគោ (ពោសោ); ក.ក. ។

៦– ចុល្លកាឡមហាកាឡវត្ថុ

សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតី មារោ វាតោ រុក្ខំវ ទុព្ពលំ
អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។

(ប្រែ) កិលេសមារ រមែងគ្របសង្កត់ នូវបុគ្គលអ្នកមានកិរិយាឃើញរឿយៗ នូវអារម្មណ៍ថាល្អជាប្រក្រតី អ្នកមិនសង្រួមក្នុងឥន្ទ្រិយទាំងឡាយ អ្នកមិនដឹងប្រមាណក្នុងភោជន ជាមនុស្សខ្ជិលច្រអូស មានព្យាយាមថោកថយនោះឯង ដូចជាខ្យល់គ្របសង្កត់ដើមឈើដែលមានកម្លាំងថយដូច្នោះ, កិលេសមារ គ្របសង្កត់នូវបុគ្គលដែលមានកិរិយាឃើញរឿយ ១ នូវ

អារម្មណ៍ថាមិនល្អជាប្រក្រតី ជាអ្នកសង្រួមដោយប្រពៃក្នុងឥន្ទ្រិយទាំងឡាយអ្នកដឹងប្រមាណក្នុងភោជន មានសទ្ធា មានព្យាយាមប្រារព្ធហើយ នោះមិនបានឡើយ ដូចជាខ្យល់គ្រប់សង្កត់ភ្នំថ្មសុទ្ធ មិនបានដូច្នោះឯង ។

## ពន្យល់វេយ្យាករណ៍

សុភានុបស្សី បុំ. (សុភ+អនុ+ទិស,ទិស>បស្ស+ណី) "អ្នកមានកិ. ឃើញរឿយ ៗ នូវអារម្មណ៍ល្អជាប្រក្រតី" វិ. សុភំ អនុបស្សិតុំ សីលមស្សា'តិ > សុភានុបស្សី (បុគ្គលោ); ស.ត. ។

វិហរន្ត គុ. (វិ+ហរ+អន្ត) "កាលគង់នៅ, កាលនៅ, កាលសម្រេចសម្រាន្តនៅ" ។

ឥន្ទ្រិយ នបុំ. (ឥន្ទ, ទ>ទ្រ+ណិយ) "(ធម្មជាត) ធ្វើនូវភាពនៃខ្លួនជាធំក្រៃលែង=(ឥន្ទ្រិយ)" វិ. ឥន្ទតិ បរមិស្ស-រិយំ ការេតី'តិ > ឥន្ទ្រិយំ (ធម្មជាតំ); ក.ក. ។

អសំវុត គុ. (ន+សំ+វុ+ត) "ដែលមិនសង្រួមហើយ, គឺ... មិនសង្រួមហើយ, -មិនរក្សាហើយ, -មិនបិទហើយ" ។

ភោជន នបុំ. (ភុជ+យុ) "(វត្ថុ)ដែលបុគ្គលគប្បីបរិភោគ,(ភោជន) វិ. ភុញ្ជិតព្វន្តិ > ភោជនំ (វត្ថុ) កម្ម. កម្ម. ។

“កិ. បរិភោគ ” វិ. ភុញ្ជិយតេ'តិ > ភោជនំ; ក.ក. ។ “(វត្ថុ)ជាទីបរិភោគ” វិ. ភុញ្ជតិ ឯត្ថា'តិ > ភោជនំ (ឋានំ) ក. អធិ. ។

អមត្តញ្ញូ គុ. (ន+មត្ត+ញា+រូ) “អ្នកមិនស្គាល់នូវប្រមាណ, អ្នកមិនដឹងនូវប្រមាណ” វិ. មត្តំ ជានាតី'តិ > មត្តញ្ញូ; ក.ក.; ន មត្តញ្ញូ > អមត្តញ្ញូ; នកយតប្បុរិស ។

កុសីត គុ.(កុ+សទ,សទ>សីទ,ទ>ត+អ) “អ្នកលិចចុះដោយការៈដែលបណ្ឌិតគប្បីធ្វើ = (អ្នកខ្ជិលច្រអូស)” វិ. កុច្ឆិតេន អាការេន សីទតី'តិ > កុសីតោ (បុគ្គលោ); ក.ក. ។

ហីនវីរិយ គុ. (ហីន+វីរិយ) “អ្នកមានព្យាយាមដ៏ថោកថយ, — សាបសូន្យហើយ, —លះបង់ហើយ” វិ. ហីនំ វីរិយំ យស្ស សោ > ហីនវីរិយោ (ជនោ) ឆ. ពហុព្វី. ។ ហីនំ វីរិយំ យេន សោ > ហីនវីរិយោ (ជនោ) តតិ. ពហុព្វី. ។ ហីន<ហា+ត. ត<ន្តៀន ។ វីរិយ<វីរ+ណិយ” កម្មនៃវីរជន = (សេចក្ដីព្យាយាម)” វិ. វីរានំ កម្មំ > វីរិយំ; កម្មតទ្ធិត ។ ឬ <វី+ឦរ+ណ្យ;” (កិច្ច) ដែលបុគ្គលគប្បីឲ្យប្រព្រឹត្តទៅដោយវិធី = (សេចក្ដីព្យាយាម)” វិ. វិធិនា ឦរយិតព្វំ

បរក្កមត្ថ·ដ្ឋិ > វីរិយំ; កម្ម. កម្ម. ។ ឬ < វិរ+ណិយ; "ការនៃសេចក្ដីអង់អាច ឬ ការនៃសេចក្ដីខ្មីខ្មាត = (ព្យាយាម) វិ. វិរស្ស ភាវោ > វីរិយំ; ការតទ្ធិត ។

បសហាតិ សទ្ទ. (បសហតិ) សព្វសទ្ទ ។ បសហាតិ កិ. "គ្របសង្កត់, សង្កត់សង្កិន < ប+សហ+អ+តិ-វិ. ។

មារ បុំ. (មរ+ណ) "(សភាវ) សម្លាប់នូវកុសលធម៌ = (មារ) វិ. កុសលធម្មេ មារេតីតិ > មារោ (សភាវោ), ក. ក. ។

ទុព្វល គុ. (ទុដ្ឋ+ពល) "មានកម្លាំងគឺទោសប្រទូស្ដហើយ = (មានកម្លាំងខ្សោយ)" វិ. ទុដ្ឋំ ពលំ យស្ស សោ > ទុព្វលោ (រុក្ខោ); ឆ. ពហុព្វី. ។

វាត បុំ. (វា+ត) "(សភាវ) ជាហេតុសាយទៅនៃក្លិននៃវត្ថុមានផ្កាជាដើម = (ខ្យល់)" វិ. វាយតិ បុប្ផាទីនំ គន្ធោ យេន សោ > វាតោ (សភាវោ) ក. ករ. ។

រុក្ខំវ សទ្ទ. (រុក្ខំ+ឥវ) បរសរលោបសន្ធិ ។ រុក្ខ < រុហ+ខ "(សភាវ) លូតលាស់ = (ដើមឈើ)" វិ. រុហតីតិ > រុក្ខោ (សភាវោ) ក. ក. ។

អសុភានុបស្សី បុ. (អសុភ+អនុ+ទិស,ទិស>បស្ស+ណី) អ្នកមានក. ឃើញរឿយ ៗ នូវអារម្មណ៍មិនល្អជាប្រក្រតី, អ្នកឃើញតាមនូវអារម្មណ៍ថាមិនល្អ ។

សុសំវុតំ គុ. (សុ+សំ+វុ+ត) "ដ៏... សង្រួមល្អហើយ; – រក្សាល្អហើយ, – បិទល្អហើយ" ។

មត្តញ្ញុ គុ. (មត្ត+ញា+រូ) "អ្នកស្គាល់នូវប្រមាណ, អ្នកដឹងនូវប្រមាណ" ។

សទ្ធ គុ. (សទ្ធា+ណ) "អ្នកមានសទ្ធា" វិ. សទ្ធាយស្សត្ថីតិ > សទ្ធោ (ជវោ); អត្ថិតទ្ធិត ។

អារទ្ធវិរិយ គុ. (អារទ្ធ+វិរិយ) "អ្នកមានព្យាយាមប្រារព្ធហើយ" វិ. អារទ្ធំ វិរិយំ យេន សោ > អារទ្ធវិរិយោ (ជវោ) គតិ. ពហុព្វី. ។ អារទ្ធ<អា+រភ+ត ។

នប្បសហតិ សទ្ធិ. (ន+បសហតិ) បរស្មៃបទ ។ នប្បសហតិ<ន+ប+សហ+អ+តិ-វិ. ។

សេលំវ សទ្ធិ. (សេលំ+ឥវ) បរស្សរលោបសន្ធិ ។ សេល<សិលា+ណ, "គំនរនៃសិលា = (ភ្នំ)" វិ. សិលានំ រាសិ > សេលោ; រាសិតទ្ធិត ។

បព្វត បុ. (បព្វ+ណ) "ភ្នំ" ។

## ៧– ទេវទត្តវត្ថុ

អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហេស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ
យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ
ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតិ ។

*(ប្រែ) បុគ្គលណា មិនទាន់ខ្ជាក់ទឹកជ្រលក់ (គឺកិលេស) ចោលចេញនៅឡើយទេ ជាអ្នកវៀរចាកកិរិយាទូន្មាននូវឥន្ទ្រិយនិងវចីសច្ចៈ នឹងស្លៀកដណ្ដប់សំពត់កាសាវៈ, បុគ្គលនោះ មិនគួរដើម្បីស្លៀកដណ្ដប់សំពត់កាសាវៈឡើយ; លុះតែបុគ្គលណាដែលខ្ជាក់ទឹកជ្រលក់ (គឺកិលេស) ចោលចេញហើយ ដម្កល់នៅដោយប្រពៃ ក្នុងសីលទាំងឡាយ ប្រកបដោយកិរិយាទូន្មាននៅឥន្ទ្រិយនិងវចីសច្ចៈ, បុគ្គលនោះឯងទើបគួរដើម្បីស្លៀកដណ្ដប់សំពត់កាសាវៈ ។*

### ពន្យល់វេយ្យាករណ៍

អនិក្កសាវៈ គុ.(អនិក្កន្ត+កសាវ) "មានទឹកចត់មិនទាន់ចេញហើយ, មានទឹកចត់គឺរាគាទិក្កិលេសមិនទាន់ចេញហើយ, មានទឹកជ្រលក់មិនទាន់ខ្ជាក់ចោលហើយ" វិ. អនិក្កន្តោ កាសាវោ យស្ស (សោ) អនិក្កសាវោ (ជនោ) ឆ.ពហុព្វី. ។ អនិក្កន្ត<ន+កម,កម>ខម+ត ។

កសាវ នបុំ. (កសវ+ណ) "(សំពត់) ដែលជនជ្រលក់ហើយ ដោយទឹកចត់" វិ. កសាវេន រត្តំ (វត្ថំ)> កាសាវំ; ពកតទ្ធិត ៗ

វត្ថ នបុំ. (វ+ថ) (វត្) សម្រាប់បិទបាំងនូវហិរិទិដ្ឋគ្គប្បៈ (នៃជន) = (សំពត់)" វិ. វុណោតិ បរិភេត្តព្វំ សំវរតិ ឯតេនា'តិ > វត្ថំ (វត្); ក.ករ. ៗ

បរិទហេស្សតិ កិ. (បរិ+ធា-ធា+ត-ទហ+អ+ស្សតិ·ភវិ.) "នឹងស្លៀកដណ្ដប់" ៗ

អបេត គុ. (អប+ឥ+ត) ទៅប្រាសហើយ, ប្រាសទៅហើយ, វៀរហើយ" ៗ

ទមសច្ច នបុំ. (ទម+សច្ច) "ទមៈនិងសច្ចៈ ការទូន្មាន និងការទៀងទាត់" វិ. ទមោ ច សច្ចំ ច > ទមសច្ចំ; សមាហារទ្វន្ទ. ៗ ទម<ទម+អ, វិ. ទមនំ>ទមោ, ភ. ក. ៗ

កាសាវមរហតិ សន្ធិ. (កាសាវំ+អរហតិ) និគ្គហិតាទេសសន្ធិ ៗ អរហតិ <អរហ+អ+តិ-វ. " គួរ, ដែលគួរ ៗ

វន្តកសាវ គុ. (វន្ត+កសាវ.) " មានទឹកចត់ខ្ជាក់ចោលហើយ " វិ. វន្តោ កសាវោ យេន សោ>វន្តកសាវោ (ជនោ) តត. ពហុព្វី. ៗ

វន្ត<វម+ត , " ខ្ជាក់ចេញហើយ , ក្អួតហើយ "
តើតហើយ " ។

សុសមាហិត គុ. (សុ+សំ+អា+ធា+ត) "តាំងមាំល្អហើយ, ដំកល់ខ្ជាប់ល្អហើយ , អ្នកមានចិត្តដំកល់មាំល្អ , អ្នកមានចិត្តដំកល់ខ្ជាប់ល្អហើយ " ។

ឧបេត គុ. (ឧប+ឥ+ត) " ចូលទៅដល់ហើយ, ចូលទៅជិតហើយ, ប្រកបហើយ " ។

## ៨– សញ្ជយស្សាគមនវត្ថុ

អសារេ សារមតិនោ សារេ ច អសារទស្សិនោ
តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា
សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ
តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា ។

(ប្រែ) ជនទាំងឡាយណា សំគាល់ថាមានខ្លឹមក្នុងធម៌ឥតខ្លឹម ឬ ឃើញថាឥតខ្លឹមក្នុងធម៌មានខ្លឹម, ជនទាំងឡាយនោះ ឈ្មោះថាមានតម្រិះខុសជាអារម្មណ៍មិនបានត្រាស់ដឹងនូវធម៌មានខ្លឹមទេ, លុះតែជនទាំងឡាយណា ដឹងនូវធម៌មានខ្លឹមថាមានខ្លឹមផង ដឹងនូវធម៌ឥតខ្លឹមថាឥតខ្លឹមផង, ជនទាំងនោះ ឈ្មោះថាមានតម្រិះត្រូវជាអារម្មណ៍ទើបបានត្រាស់ដឹងនូវធម៌មានខ្លឹម ។

## ពន្យល់វេយ្យាករណ៍

អសារេ — គុ. (ន+សារ) "(ធម៌) មានខ្លឹមមិនមាន, ឥតខ្លឹម" វិ. នត្ថិ សារោ អស្សា'តិ> អសារោ (ធម្មោ), នបុព្វ. ឆ. ពហុព្វី. ។

សារមតី — គុ. (សារមតិ+ណី) "មានកិរិយាដឹងថាមានខ្លឹម" វិ. សារោ'តិ មតិ យស្ស អត្ថី'តិ> សារមតី (ជនោ); អត្ថិតទ្ធិត. ។ មតិ<មន+តិ; វិ. មននំ> មតិ; ភ.ក. ។

អសារទស្សី — បុំ. (អសារ+ទិស, ទិស>ទស្ស+ណី) "អ្នកមានកិរិយាឃើញនូវធម៌មិនមានខ្លឹមជាប្រក្រតី" វិ. អសារំ (ធម្មំ) បស្សិតុំ សីលមស្សា'តិ> អសារទស្សី (ជនោ) ស.ត. ។

នាធិគច្ឆន្តិ — សន្ធិ. (ន + អធិគច្ឆន្តិ) បុព្វសរលោបសន្ធិ និងបរទ្វេភាវសន្ធិ ។ អធិគច្ឆន្តិ < អធិ+គម, ម> ច្ឆ+អ+អន្តិ-រ.; "រមែងបាន, លុះ, ត្រាស់ដឹង" ។

មិច្ឆាសង្កប្បគោចរា — គុ. (មិច្ឆាសង្កប្ប+គោចរ) "មានតម្រិះខុសជាអារម្មណ៍" វិ. មិច្ឆាសង្កប្បោ គោចរោ យស្ស (សោ)> មិច្ឆាសង្កប្បគោចរោ; ឆ. ពហុព្វី. ។

សារញ្ច — សន្ធិ ( សារំ+ច ) និគ្គហិតាទេសសន្ធិ ។

សារតោ — អ.ន. ( សារ+តោ ) " អំពីធម៌មានខ្លឹម " ។

ញត្វា — អ. ( ញា+ត្វា ) "ដឹងហើយ, ជ្រាបហើយ" ។

សម្មាសង្កប្បគោចរា — គុ. ( សម្មាសង្កប្ប + គោចរ ) មានតម្រិះត្រូវជាអារម្មណ៍ " ធ. ពហុព្វី. ។

## ៩– នន្ទត្ថេរវត្ថុ

យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ
យថា អគារំ សុច្ឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ
ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

(ប្រែ) គ្រាប់ភ្លៀង រមែងធ្លាក់ធ្លុះរហូត នូវផ្ទះដែលបុគ្គលប្រក់មិនល្អដូចម្ដេចមិញ, រាគៈ រមែងធ្លាក់ធ្លុះរហូត នូវចិត្តដែលបុគ្គលមិនបានចំរើនហើយក៏ដូច្នោះដែរ, គ្រាប់ភ្លៀង • មិនបានធ្លាក់ធ្លុះរហូតនូវផ្ទះដែលបុគ្គលប្រក់ល្អដូចម្ដេចមិញ រាគៈមិនបានធ្លាក់ធ្លុះរហូត នូវចិត្តដែលបុគ្គលចំរើនហើយដោយប្រពៃ ក៏យ៉ាងនោះដែរ ។

### ពន្យល់វេយ្យាករណ៍

យថា — អ. សព្វ. ( យ+ថា ) "បការឯណា" វិ. យោ បការោ > យថា: " នូវបការឯណា " វិ. យំ បការំ > យថា ។ល។

អគារ ពុ.,ឧបុ. "ផ្ទះ, រោង" ។

ទុច្ឆន្ន គុ. (ទុ + ឆទ + ត, ត > អន្ន) "គឺ... ប្រក់មិនល្អ, — បិទបាំងមិនល្អហើយ" ។

វុដ្ឋិ ឥ. (វស្ស+តិ) "កិរិយាបង្អុរ=(ភ្លៀង)" វិ. វស្សនំ > វុដ្ឋិ; ក. ក. ។

សមតិវិជ្ឈតិ កិ. (សំ + អតិ + វិធ + យ + តិ-វ.) "ចាក់ធ្លុះកន្លងព្រម, លិចស្រោច," ។

អភាវិត គុ. (ន+ភូ+ណេ+អា+ត) "គឺ... មិនចំរើនហើយ, — មិនអប់រំហើយ" ។

ចិត្ត ឧបុ. (ចិន្ត+ត) "(ធម្មជាត) ត្រិះរិះនូវអារម្មណ៍" វិ. អារម្មណំ ចិន្តេតីតិ > ចិត្តំ (ធម្មជាតំ); ក. ក. ។

រាគ ពុ. (រញ្ជ+ណ) "សេចក្តីតេកអរ = (តម្រេក)" វិ. រញ្ជនំ > រាគោ; ក.ក. ។

សុច្ឆន្ន គុ. (សុ+ឆទ+ត,ត>អន្ន) "គឺ... ប្រក់ល្អហើយ, បិទបាំងល្អហើយ" ។

សុភាវិត គុ. (សុ+ភូ+ណេ–អេ.+ត) "ដែល... ចំរើនល្អហើយ, អប់រំល្អហើយ"

## ១០– ចុន្ទសូករិកវត្ថុ

ឥធ សោចតិ បេច្ច សោចតិ
បាបការី ឧភយត្ថ សោចតិ
សោ សោចតិ សោ វិហញ្ញតិ
ទិស្វា កម្មកិលិដ្ឋមត្តនោ ។

*(ប្រែ) ជនអ្នកធ្វើកម្មអាក្រក់ រមែងសោកក្នុងលោកនេះ, សោកក្នុងលោកខាងមុខ ឈ្មោះថាសោកក្នុងលោកទាំងពីរ, ជននោះរមែងសោក រមែងក្ដៅក្រហាយ ព្រោះឃើញកម្មដ៏សៅហ្មងរបស់ខ្លួន ។*

### ពន្យល់វេយ្យាករណ៍

ឥធ អ.សព្វ. (ឥម+ធ) ក្នុងទីនេះ, "ក្នុង... នេះ" វិ. ឥមស្មឹ ហិ (ធ) > ឥធ ។

សោចតិ កិ. (សុច+អ+តិ-វ.) "សោក, សោយសោក, សោកស្ដាយ, រងសោក" ។

បេច្ច អ. (បរ+ឥ+ត្វា) ទៅកាន់លោកខាងមុខហើយ ឬទៅហើយកាន់លោកខាងមុខ" ។

បាបការី បុំ. (បាប+ករ+ណី) "អ្នកមានកិរិយាធ្វើនូវបាបជាប្រក្រតី" វិ. បាបំ កាតុំ សីលំ យស្ស (សោ) > បាបការី; ស.ត. ។ "អ្នកធ្វើនូវបាបដោយប្រក្រតី" វិ. បាបំ ការេតិ សីលេនា'តិ > បាបការី; ក.ត. ។

ឧភយត្ថ អ.សព្វ. (ឧភយ+ត្ថ) "ក្នុង...ទាំងពីរ" ។

វិហញ្ញតិ កិ. (វិ+ហន+យ+តេ-តិ.) "លំបាក, តឹងចិត្ត" ។

ទិស្វា អ. (ទិស+ត្វា) "ឃើញហើយ, ..." ។

កម្មកិលិដ្ឋមត្តនោ សន្ធិ. (កម្មកិលិដ្ឋំ+អត្តនោ) និគ្គហិតាទេសសន្ធិ ។ កម្មកិលិដ្ឋ<កម្ម+កិលិដ្ឋ, "កម្មដ៏សៅហ្មង" វិ. កម្មំ កិលិដ្ឋំ: កម្មកិលិដ្ឋំ; កិលិដ្ឋ<កិលិស+ត ។

## ១១– ធម្មិកឧបាសកវត្ថុ

ឥធ មោទតិ បេច្ច មោទតិ
កតបុញ្ញោ ឧភយត្ថ មោទតិ
សោ មោទតិ សោ បមោទតិ
ទិស្វា កម្មវិសុទ្ធិមត្តនោ ។

(ប្រែ) ជនដែលមានបុណ្យធ្វើហើយ រមែងរីករាយក្នុងលោកនេះ, រីករាយក្នុងលោកខាងមុខ, ឈ្មោះថារីករាយក្នុងលោកទាំងពីរ, ជននោះរីករាយរឹតតែរីករាយពេកក្រៃលែង ព្រោះឃើញអំពើដ៏បរិសុទ្ធរបស់ខ្លួន ។

### ពន្យល់វេយ្យាករណ៍

៩៨, បេច្ច ឧភយត្ថ ទិស្វា ចូលមើលរឿងចុន្ទសូករិក លេខ ១០ ក្នុងយមកវគ្គទី ១ ។

មោទតិ កិ. (មុទ+អ+តិ-តិ.) "រីករាយ, ..." ។

កតបុញ្ញ គុ.(កត+បុញ្ញ) "មានបុណ្យធ្វើហើយ" វិ. កតំ បុញ្ញំ យេន សោ>កតបុញ្ញោ; តតិ.ពហុព្វី. ។ បុញ្ញ<បុ+ណ្យ;"(ធម្មជាត)ជំរះ=(បុណ្យ).ឬ(ធម្មជាត) ជំរះនូវសន្តានចិត្តនៃសត្វ" វិ. បុជាតី'តិ>បុញ្ញំ (ធម្មជាតំ) ។ សត្តសន្តានំ បុជាតិ វិសោធេតី'តិ > បុញ្ញំ (ធម្មជាតំ); ក. ក. ។

បមោទតិ កិ.(ប+មុទ+អ+តិ-វ.) "រីករាយទូទៅ" ។

កម្មវិសុទ្ធិ ឥ. (កម្ម+វិសុទ្ធិ) "សេចក្តីបរិសុទ្ធិនៃកម្ម" វិ. កម្មស្ស សុទ្ធិ>កម្មវិសុទ្ធិ; ឆ.តប្បុ. ។

១៦ – ទេវទត្តវត្ថុ

ឥធ តប្បតិ បេច្ច តប្បតិ
បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ
ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

(ប្រែ) បុគ្គលអ្នកធ្វើបាប រមែងក្តៅក្រហាយក្នុងលោកនេះ, ក្តៅក្រហាយក្នុងលោកខាងមុខ, ឈ្មោះថាក្តៅក្រហាយក្នុងលោកទាំងពីរ, ក្តៅក្រហាយដោយគិតថា "បាបអាត្មាអញបានធ្វើហើយ" ទៅកាន់ទុគ្គតិក៏ក្តៅក្រហាយដោយក្រៃលែង ។

## ពន្យល់វេយ្យាករណ៍

ឥធ, បេច្ច, ឧភយត្ថ, បាបការី ចូរមើលរឿងចុន្ទសូករិក លេខ ១០ ក្នុងយមកវគ្គទី ១ ។

តប្បតិ កិ. (តប+យ+តិ-រ.) “ក្ដៅក្រហាយ” ។

បាប នបុំ. (ប+បា+អ) “(កម្ម) រក្សានូវអបាយ” វិ. អបាយំ បាតិ រក្ខតីតិ > បាបំ (កម្មំ); ក. ក. ។ “(កម្ម) ជាដែនរក្សានូវខ្លួននៃសុខ ; បាតិ រក្ខតិ អត្តានំ អស្មាតិ > បាបំ (កម្មំ); ក. អបាទាន. ។ បាប < ប + អប+អ ; “(កម្ម) ជាគ្រឿងដល់នូវអបាយ (នៃសត្វ) វិ. បំ អបាយំ បេតិ គច្ឆតិ តេនាតិ > បាបំ (កម្មំ) ក. ករ. ។ បាប< ប+ អាប+អ; “(កម្ម) ញ៉ាំងសត្វឲ្យដល់នូវទុគ្គតិ” វិ. ទុគ្គតឹ បាបេតីតិ > បាបំ (កម្មំ); ក. ក. ។

កតន្តិ សន្ធិ. (កតំ+ឥតិ) និគ្គហិតាទេសសន្ធិ និងបរសរលោបសន្ធិ ។

កត កិ. (ករ+ត) “ធ្វើហើយ, ដែល...ធ្វើហើយ” ។

ទុគ្គតិ ឥ. (ទុ+គតិ) “ដំណើរទៅ (ដែលបណ្ឌិត) ខ្ពើមក្រៃលែង” វិ. ទុដ្ឋុ កុច្ឆិតា គតិ > ទុគ្គតិ; វិ. បុ. ។ គតិ< គម+តិ; វិ. គមនំ > គតិ; “ដំណើរទៅ” ក. ក. ។

គត កិ. (គម + ត) “ទៅហើយ, ដល់ហើយ” ។

## ១៣- សុមនទេវីវត្ថុ

ឥធ នន្ទតិ បេច្ច នន្ទតិ
កតបុញ្ញោ ឧភយត្ថ នន្ទតិ
បុញ្ញំ មេ កតន្តិ នន្ទតិ
ភិយ្យោ នន្ទតិ សុគតឹ គតោ ។

*(ប្រែ) បុគ្គលអ្នកបានធ្វើបុណ្យហើយ រមែងត្រេកអរក្នុងលោកនេះ, ត្រេកអរក្នុងលោកខាងមុខ, ឈ្មោះថាត្រេកអរក្នុងលោកទាំងពីរ, ត្រេកអរដោយគិតថា "បុណ្យអាត្មាអញបានធ្វើហើយ" ទៅកាន់សុគតិក៏ត្រេកអរដោយក្រៃលែង ។*

### ពន្យល់វេយ្យាករណ៍

ឥធ, បេច្ច, កតបុញ្ញ, ឧភយត្ថ, បុញ្ញ, កតន្តិ, គត

ចូរមើលរឿងទេវទត្តលេខ ១២ និងរឿងធម្មិកឧបាសកលេខ ១១ ។

នន្ទតិ កិ. ( នន្ទ + អ + តិ – វ.) " ត្រេកអរ, រីករាយ " ។

សុគតិ នា. (សុ + គតិ) " ដំណើរល្អ " វិ. សុន្ទរា គតិ > សុគតិ; ឥ. បុ. ។

## ១៤– ទ្វេសហាយកភិក្ខុវត្ថុ

ពហុម្បិ ចេ សហិតំ ភាសមានោ
ន តក្ករោ ហោតិ នរោ បមត្តោ

គោបោវ គាវោ គណយំ បរេសំ
ន ភាគវា សាមញ្ញស្ស ហោតិ ។
អប្បម្បិ ចេ សហិតំ ភាសមានោ
ធម្មស្ស ហោតិ អនុធម្មចារី
រាគញ្ច ទោសញ្ច បហាយ មោហំ
សម្មប្បជានោ សុវិមុត្តចិត្តោ
អនុបាទិយានោ ឥធ វា ហុរំ វា
ស ភាគវា សាមញ្ញស្ស ហោតិ ។

*(ប្រែ) បើជនណា ពោលនូវពុទ្ធវចនៈ មានប្រមាណច្រើន តែជាអ្នកមិនធ្វើតាមពុទ្ធវចនៈនោះ ជាអ្នកប្រមាទ, ជននោះមិនបាននូវចំណែកនៃសាមញ្ញផលទេ, ដូចជាគង្វាលគោកាលរាប់គោទាំងឡាយ ឲ្យជនដទៃដូច្នោះ ។ បើជនណាពោលនូវពុទ្ធវចនៈសូម្បីបន្តិច ប៉ុន្តែជាអ្នកប្រព្រឹត្តធម៌តាមគន្លងធម៌ លះបង់រាគៈ ទោសៈ មោហៈកំណត់ដឹង (នូវធម៌ ដែលគួរកំណត់ដឹង) មានចិត្តរួចស្រឡះដោយប្រពៃមិនប្រកាន់ (នូវខន្ធ) ក្នុងលោកនេះផង ក្នុងលោកខាងមុខផង, ជននោះទើបជាអ្នកបាននូវចំណែកនៃសាមញ្ញផល ។*

*ពន្យល់វេយ្យាករណ៍*

ពហុម្បិ សន្ធិ. (ពហុំ+បិ) និគ្គហិតាទេសសន្ធិ ។

សហិត គុ. ( សហ+ហិត ) " ប្រព្រឹត្តទៅមួយអន្លើដោយប្រយោជន៍ " វិ. សហ ហិតេន យំ វត្តតីតិ សហិតំ ( ពុទ្ធវចនំ ) សហបុព្វបទពហុព្វី. ។

កាសមាន គុ. ( កាស+មាន ) " កាលពោល ។

តក្ករ បុំ. ( ត+ករ+អ ) " អ្នកធ្វើតាម ( នូវពុទ្ធវចនៈ" ) នោះ វិ. តំ ( ពុទ្ធវចនំ ) ករោតីតិ > តក្ករោ; ក. ក. ។

ហោតិ កិ. ( ហូ+អ+តិ-វ.( " មាន, រមែងមាន " ។

នរ បុំ. ( និ+អរ ) អ្នកនាំទៅ = ( នរៈ ) វិ. នេតីតិ > នរោ ( ជនោ ) ក.ក. ។ ឬ < នរ+អ វិ. នរតីតិ > នរោ ( បុរិសោ ) ក. ក. ។

បមត្ត គុ. ( ប+មទ+ត ) " ប្រមាទហើយ, ធ្វេសប្រហែសហើយ,.. " ។

គោបោវ សទ្ទិ. ( គោបោ+ឥវ ) បរសរលោបសន្ធិ ។ គោប < គោ+បា+ណ ; អ្នករក្សានូវគោ = ( គង្វាលគោ ) វិ. គាវោ បាតីតិ > គោបោ ( ជនោ ) ក. ក. ។

គណយន្ត គុ. ( គណ+យ+អន្ត ) " កាលរាប់, កាលគិត, " គណយំ < គណយន្ត+សិ, +ន្ត+សិ > ំ ។

ភាគវា គុ. ( ភាគ+វន្តុ ) " អ្នកមានចំណែក " វិ. ភាគោ យស្សត្ថីតិ > ភាគវា ; អត្ថិអត្ថ ។

សាមញ្ញ នបុំ. ( សមណ+ណ្យ " ភាវៈនៃសមណៈ = (សាមញ្ញផល) " វិ. សមណស្ស ភាវោ>សាមញ្ញំ; ភាវតទ្ធិត ។

អប្បម្បិ សន្ធិ. (អប្បំ+បិ) និគ្គហិតាទេសសន្ធិ ។

អនុធម្មចារី បុំ. ( អនុធម្ម+ចរ+ណី ) " អ្នកមានកិរិយាប្រព្រឹត្តតាមធម៌ជាប្រក្រតី" វិ. អនុធម្មំ ចរតិ សីលមស្សាតិ> អនុធម្មចារី; ស. ត. ។

ភគ បុំ. ចូរមើលរឿងទទ្ធគេលេខ៩ ក្នុងយមកវគ្គទី ១ ។

ទោសញ្ច សន្ធិ. ( ទោសំ+ច ) និគ្គហិតាទេសសន្ធិ ។

ទោស " កិរិយាប្រទូស្ត " < ទុស+ណ, វិ. ទុស្សនំ> ទោសោ ។

បហាយ អ. ( ប+ហា+ត្វា,ត្វា>យ ) " លះបង់ហើយ, ... " ។

មោហ បុំ. ( មុហ+ណ ) " សេចក្តីវង្វេង = ( មោហ ) វិ. មុយ្ហនំ>មោហោ ។

សម្បជាន បុំ. ( សម្+ប+ញា+យុ ) " អ្នកកំណត់ដឹងច្បាស់, អ្នកដឹងច្បាស់, ... " វិ. សម្មា បជានាតីតិ> សម្បជានោ; ក. ក. ។ ឬ <សម្មាប+ញា+អន; " កាលកំណត់ដឹងច្បាស់, កាលដឹងច្បាស់ " ។

សុវិមុត្តចិត្ត គុ. ( សុវិមុត្ត+ចិត្ត ) " មានចិត្តរួចស្រឡះដោយប្រពៃ "

វិ. សុវិមុត្តំ ចិត្តំ យស្ស សោ>សុវិមុត្តចិត្តោ.

៨. ពហុព្វី. ។ សុវិមុត្ត>សុ+វិ+មុច+ត ។

អនុបាទិយាន បុំ. (ន+ឧប+អា+ទា–អាទេសជាទិ+យ–អា+យុ) "អ្នកមិនចូលទៅកាន់យក, អ្នកមិនប្រកាន់មាំ" វិ. ន ឧបាទិយតីតិ> អនុបាទិយានោ; ក.ក.។ ឬ <ន+ឧប+អា+ទា, អាទេសជាទី+យ–អា+អាន; "កាលមិនចូលទៅកាន់យក, កាលមិនប្រកាន់មាំ ។

ចប់យមកវគ្គទី ១

---

## អប្បមាទវគ្គទី ២

### ១– សាមាវតីវត្ថុ

អប្បមាទោ អមតំ បទំ   បមាទោ មច្ចុនោ បទំ
អប្បមត្តា ន មីយន្តិ   យេ បមត្តា យថា មតា
ឯតំ វិសេសតោ ញត្វា   អប្បមាទម្ហិ បណ្ឌិតា
អប្បមាទេ បមោទន្តិ   អរិយានំ គោចរេ រតា
តេ ឈាយិនោ សាតតិកា   និច្ចំ ទឡ្ហបរក្កមា
ផុសន្តិ ធីរា និព្វានំ   យោគក្ខេមំ អនុត្តរំ ។

(ប្រែ) សេចក្ដីមិនប្រមាទ ជាផ្លូវនៃព្រះនិព្វាន, សេចក្ដីប្រមាទ ជាផ្លូវនៃមច្ចុ, ជនទាំងឡាយមិនប្រមាទ ទើបមិនស្លាប់, ជនទាំងឡាយ

ឯណាប្រមាទ, ជនទាំងនោះទុកដូចជាស្លាប់, អ្នកប្រាជ្ញទាំងឡាយ ដឹងនូវសេចក្ដីនេះដោយប្លែកគ្នា ហើយឋិតនៅក្នុងអប្បមាទធម៌ រីករាយក្នុងអប្បមាទធម៌, អ្នកប្រាជ្ញទាំងឡាយនោះ រមែងត្រេកអរក្នុងធម៌ជាទីគោចរនៃពួកព្រះអរិយៈ ជាអ្នកមានធម៌ជាគ្រឿងដុតនូវបច្ចនិកកិលេស មានព្យាយាមរឿយ ៗ មានសេចក្ដីប្រឹងប្រែងដ៏មុតមាំជានិច្ច ទើបបាននូវព្រះនិព្វានជាទីក្សេមចាកយោគៈ ដែលឥតគុណជាតដទៃប្រសើរជាង ។

## ពន្យល់វេយ្យាករណ៍

អប្បមាទ បុំ. ( ន+ប+មទ+ណ ) "កិរិយាមិនស្រវឹងទៅ, សេចក្ដីមិនប្រមាទ, សេចក្ដីមិនធ្វេសប្រហែស" វិ. អប្បមជ្ជនំ > អប្បមាទោ; ក. ក. ។

អមតំបទំ សន្ធិ. ( អមតបទំ ) និគ្គហិតាគមសន្ធិ ។ អមតំ បទំ "ផ្លូវនៃព្រះនិព្វានឈ្មោះអមតៈ" វិ. អមតស្ស បទំ > អមតំបទំ; ឆ. តប្បុ. ។

អមត < ន+មត; "មិនស្លាប់, មិនស្លាប់ហើយ, និព្វានឈ្មោះអមតៈ" ។

បមាទ បុំ. (ប+មទ+ណ) "កិរិយាស្រវឹងទៅ, សេចក្ដីប្រមាទ, សេចក្ដីធ្វេសប្រហែស, វិ. បមជ្ជនំ > បមាទោ; ក. ក. ។

មច្ចុ ឥបុំ. ( មរ+ត្យុ ) "សេចក្ដីស្លាប់" វិ. មរណំ > មច្ចុ; ក. ក. ។

បទំ — បុំ.,នបុំ. ( បទ+អ ) "ផ្លូវ, ជើង, ឧបាយ, ព្រះនិព្វាន, ហេតុ, ..." ។

អប្បមត្តា — គុ. ( ន+ប+មទ+ត ) " មិនស្រវឹងខ្លួនទៅហើយ, ... " ។

មីយន្តិ — កិ. ( មរ>មីយ+អ+អន្តិ.វ.) " ស្លាប, ងាប់,... " ។

បមត្តា — គុ. ( ប+មទ+ត ) " ស្រវឹងខ្លួនទៅហើយ,... " ។

មតា — គុ. ( មរ+ត ) " ស្លាប់ហើយ , ងាប់ហើយ " ។

ញត្វា — អ. ( ញា+ត្វា ) " ដឹងហើយ , ជ្រាបហើយ , ... "

បណ្ឌិត — បុំ. ( បណ្ឌា+ឥត ) "មានប្រាជ្ញាកើតព្រម វិ. បណ្ឌា ពុទ្ធិ សញ្ជាតា អស្សាតិ > បណ្ឌិតោ; សញ្ជាតត្ថិត ។

បមោទន្តិ — កិ. ( ប+មុទ+អ+អន្តិ-វ. ) រីករាយខ្លួនទៅ,... ។

អរិយ — បុំ. ( អរ+ណ្យ+ឥ-អា. ) " អ្នកសម្លាប់នូវសត្រូវគឺកិលេស=( ព្រះអរិយ )" វិ. កិលេសារយោ ហន្តីតិ> អរហោ , សោ ឯវ > អរិយោ ។ " អ្នកឆ្ងាយចាកកិលេស " វិ. កិលេសេហិ អារកាតិ > អរិយោ (ផ្លាស់ អារកជាអរិយ) ។

គោចរ — បុំ. ( គោ+ចរ+អ ) " ( ទ្វារ ) ជាទីត្រាច់ទៅនៃឥន្ទ្រិយ" វិ. គោ ឥន្ទ្រិយានិ ចរន្ត្យត្រស្មាតិ> គោចរោ (ទ្វារ); ត.អធិ. ។

រត — គុ. [ រម+ត. ] "រីករាយហើយ, ត្រេកអរហើយ" ។

ឈាយី — បុំ. [ ឈេ, ឯថៃឈេ>អាយ>ណី ] "អ្នកដុតទូវនីវរណធម៌ដែលជាសត្រូវ, អ្នកដុត". វិ. បច្ចនិកេ នីវរណធម្មេ ឈាយតីតិ>ឈាយី; ក.ក.។ ឬ វិ. ឈាយតីតិ > ឈាយី; ក. ក. ។

ទឡ្ហបរក្កម — គុ. [ ទឡ្ហ+បរក្កម ] "មានសេចក្តីប្រឹងប្រែងដ៏មុំមាំ; មានសេចក្តីព្យាយាមដ៏មាំមួន" វិ. ទឡ្ហោ បរក្កមោ យស្ស សោ > ទឡ្ហបរក្កមោ; ឆ.ពហុព្វី ។ បរក្កម<បរ+កម+អ; "(សកាវ) ឈានទៅកាន់ទីដទៃ ៗ =(ព្យាយាម)" វិ. បរំ បរំ ឋានំ អក្កមតីតិ> បរក្កមោ (សភាវោ) ក.ក. ។ (សភាវ) ឈានកន្លងទូវកោសជ្ជៈជាសត្រូវ" វិ. បរំ បច្ចនិកភូតំ កោសជ្ជំ អក្កមតីតិ>បរក្កមោ (សភាវោ) ក. ក. ។

ផុសន្តិ — កិ. [ ផុស+អ+អន្តិ-វ. ] ពាល់, ស្ទាប, អង្អែល, ប៉ះ, ពាល់ត្រូវ, បាន" ។

និព្វាន — នបុំ. [ និ+វាន ] (ធម្មជាត) ចេញចាកតណ្ហា (ព្រះនិព្វាន) វិ. និក្ខន្តំ វានតោ>និព្វានំ (ធម្មជាតំ) បញ្ច. តប្បុ. ។ (ធម្មជាត) ដែលតណ្ហាមិនមាន

វិ. នត្ថិ ឯត្ថ ភាឆត្តិ > ធិញ្ញាណំ (ធម្មជាតំ) នបុព្វបទសត្តមីពហុព្វី. ។

ធីរ — បុំ. (ធី+រ) "មានប្រាជ្ញា=(អ្នកប្រាជ្ញ)" វិ. ធី បញ្ញា អស្ស អត្ថីតិ > ធីរោ, អត្ថិតទ្ធិត ។

យោគក្ខេម — នបុំ. (យោគ+ខេម) "សេចក្តីក្សេមចាកយោគៈ" វិ. យោគា ខេមំ > យោគក្ខេមំ; បញ្ច. តប្បុ. ។ គុ. "មានសេចក្តីក្សេមចាកយោគៈ" វិ. យោគក្ខេមំ យស្សត្ថីតិ > យោគក្ខេមំ (ធិញ្ញាណំ) អត្ថិតទ្ធិត ។ ខេម < ខិ+ម ; "(គុណជាត) ជាគ្រឿងអស់ទៅនៃភ័យមានភ័យគឺកង្ខៈជាដើម" វិ. ខយន្តិ ឯតេន ភគត្តិអាទយោ'តិ > ខេមំ (គុណជាតំ); ក. ករ. ។

អនុត្តរ — គុ. (ន+ឧត្តរ) "មិនមានគុណជាតដទៃក្រៃលែងជាង=(ប្រសើរ)".. វិ. នត្ថិ ឯតស្ស ឧត្តរោ'តិ > អនុត្តរំ (ធិញ្ញាណំ); នបុព្វបទ ន. ពហុព្វី. ។

## ២ – កុម្ភឃោសកវត្ថុ

ឧដ្ឋានវតោ សតីមតោ សុចិកម្មស្ស និសម្មការិនោ

សញ្ញតស្ស ច ធម្មជីវិនោ អប្បមត្តស្ស យសោភិវឌ្ឍតិ ។

(ប្រែ) យសរមែងចំរើនចំពោះ ដល់បុគ្គលអ្នកមានព្យាយាម មានស្មារតី មានការងារស្អាត អ្នកពិចារណាហើយទើបធ្វើ អ្នកសង្រួម អ្នកចិញ្ចឹមជីវិតប្រកបដោយធម៌ អ្នកមិនប្រមាទ ។

## ពន្យល់វេយ្យាករណ៍

ឧដ្ឋានវន្តុ គុ. ( ឧដ្ឋាន+វន្តុ ) "មានព្យាយាមជាគ្រឿងតាំងឡើង, មានសេចក្ដីខ្នះខ្នែង" វិ. ឧដ្ឋានំ (យស្ស អត្ថិ> ឧដ្ឋានវា ; អត្ថត្ថិត ។ ឧដ្ឋាន< ឧ + ឋា + យុ "កិរិយាតាំងឡើង, កិរិយាក្រោកឡើង, សេចក្ដីព្យាយាម, សេចក្ដីក្រវើនក្រវែង" វិ. ឧដ្ឋហតិ (ឯតេនាតិ> ឧដ្ឋានំ ក.ក. ។ ឧដ្ឋានវតោ < ឧដ្ឋានវន្តុ+ស, ន្តុ+ស > តោ ។

សតិមន្តុ គុ. (សតិ+មន្តុ) "មានសតិ, មានស្មារតី, មានសេចក្ដីរឭក" វិ. សតិ (យស្ស អត្ថិ> សតិមា; អត្ថត្ថិត ។ សតិមតោ < សតិមន្តុ+ស, ន្តុ+ស > តោ ។

សុចិកម្ម គុ. ( សុចិ+កម្ម ) "មានការងារស្អាត" វិ. សុចិ កម្មំ យស្ស (សោ> សុចិកម្មោ; ឆ. ពហុព្វី. ។

និសម្មការី បុំ. ( និសម្ម+ករ+ណី ) "អ្នកមានកិរិយាពិចារណាហើយទើបធ្វើជាប្រក្រតី" វិ. និសម្ម ការេតុំ សីលំ យស្ស (សោ> និសម្មការី; ស.ត. ។

សញ្ញត គុ. (សំ+យម+ត) "សង្រួមហើយ, ប្រុងប្រយ័ត្នហើយ,..."

ធម្មជីវី បុំ. ( ធម្ម+ជីវ+ណី ) "អ្នករស់នៅដោយធម៌តាមប្រក្រតី" វិ. ធម្មេន ជីវតិ សីលេនា'តិ > ធម្មជីវី; ក. ត. ។

អប្បមត្ត គុ. ( ន+ប+មទ+ត ) "មិនស្រវឹងទូទៅហើយ,..."

យសោភិវឌ្ឍតិ សន្ធិ. ( យសោ+អភិវឌ្ឍតិ ) "បរសរលោបសន្ធិ ។

យស បុំ. ( យជ,ជ > ស+អ ) "(គុណធម៌) ជាគ្រឿងបូជា (នៃជន;"= (យស, អានុភាព, ឥស្សរភាព, បរិវារ,...)" វិ. យជតិ ឯតេនា'តិ > យសោ (គុណជម្មោ) ក. ករ. ។

អភិវឌ្ឍតិ កិ. ( អភិ+វឌ្ឍ+អ–តិ–វ. ) "រមែងចំរើនចំពោះ, ចំរើនក្រៃលែង" ។

១ - ចូឡបន្ថកត្ថេរវត្ថុ

ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច
ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

(ប្រែ) ទឹកជំនន់គឺកិលេស គ្របសង្កត់នូវកោះឯណាពុំបាន, អ្នកប្រាជ្ញគប្បីធ្វើនូវកោះនោះ ( ឲ្យកើតឡើង ) ដោយសេចក្តីព្យាយាមផង ដោយសេចក្តីមិនប្រមាទផង ដោយសេចក្តីសង្រួមផង ដោយការទូន្មាននូវឥន្ទ្រិយផង ។

## ពន្យល់វេយ្យាករណ៍

ឧដ្ឋាន ចូរមើលរឿងកុម្ភឃោសកលេខ ៤ ក្នុងអប្បមាទវគ្គទី ២ ។

អប្បមាទ ចូរមើលរឿងសាមាវតីលេខ ១ ក្នុងអប្បមាទវគ្គទី ២ ។

សញ្ញម បុ. (សំ+យម+ណ) "ការសង្រួម, សេចក្ដីប្រុងប្រយ័ត្ន, ..." វិ. សញ្ញមិយតេតិ > សញ្ញមោ, ក. ក. ។

ទម បុ. (ទម+អ) "សេចក្ដីទូន្មាន, ការយាគូន្មាន" វិ. ទមនំ > ទមោ ក. ភ. ។

ទីប បុ. "ទ្វីប, កោះ, ព្រះទិញាន, ប្រទីប" ។

កយិរាថ កិ. (ករ+យិរ+ឯថ-ស.) "គប្បីធ្វើ, ..." ។

មេធាវី បុ. (មេធា+វី) "មានប្រាជ្ញា=(អ្នកប្រាជ្ញ)" វិ. មេធា យស្ស អត្ថីតិ > មេធាវី; តទ្ធិត ។

ឱឃ បុ. (អវ,អោ>ឱ+ហន,ហន>ឃ+អ); "ការជៀតជៀនវាណ៍ទប =(ជំនន់; អន្លង់, ការប្រមុំ, សំទុះ, កំឡាំង)" វិ. អវ ឃាតេតិ > ឱឃោ ; ក. ភ. ។

នាភិកីរតិ សទ្ទ. (ន+អភិកីរតិ) បុព្វសរលោបសន្ធិមីអនេកបទសន្ធិ ។
(អភិកិរតិ<អភិ+កីរ+អ+តិ-វ.) "គ្របសង្កត់, ជះជន់; ផន់លិច" ។

៤ - ពាលជនវគ្គ

បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំ រក្ខតិ

មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ

អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។

(ប្រែ) ពួកជនពាលឥតប្រាជ្ញាតែងប្រកបរឿយ ៗ នូវសេចក្ដីប្រមាទ (ប្រហែសធ្វេស), អ្នកប្រាជ្ញរមែងរក្សានូវសេចក្ដីមិនប្រមាទ (មិនប្រហែសធ្វេស)ដូចជាគេរក្សានូវទ្រព្យដ៏ថ្លៃថ្លា ។ អ្នកទាំងឡាយកុំប្រកបរឿយ ៗ នូវសេចក្ដីប្រមាទឡើយ, កុំធ្វើសេចក្ដីស្និទ្ធស្នាលដោយសេចក្ដីត្រេកត្រអាលក្នុងកាមឡើយ, ដ្បិតថា បុគ្គលមិនប្រមាទមានព្យាយាមជាគ្រឿងដុតបំផ្លាញនូវកិលេស រមែងដល់នូវសេចក្ដីសុខដ៏ទូលាយ ។

ពន្យល់វេយ្យាករណ៍

បមាទ, អប្បមាទ, អប្បមត្ត ចូរមើលរឿងសមាវតី លេខ ១ ក្នុងអប្បមាទវគ្គទី ២ ។

មេធាវី ប៉ុ. ចូរមើលរឿងចូឡបន្ថកត្ថេរ លេខ ៣ ក្នុង អប្បមាទវគ្គ ទី ២ ។

បមាទមនុយុញ្ជន្តិ សន្ធិ. (បមាទំ+អនុយុញ្ជន្តិ) និគ្គហិតាទេសសន្ធិ ។

អនុយុញ្ជន្តិ កិ. (អនុ+យុជ+អ+អន្តិ-វ.បុ.ន.អ.) "ប្រកបរឿយ ៗ, ប្រកបតាម,..." ។

ពាល ប៉ុ. (ទ្វេ,ទ្វេ>ពា+លុ+អ) "អ្នកកាត់បង់នូវប្រយោជន៍ទាំងពីរ(បុគ្គលពាល,-ល្ងង់)" វិ. ទ្វេ អត្ថេ លុនាតីតិ > ពាលោ; ក. ក. ។

ទុម្មេធី បុំ. (ទុម្មេធា+ឥ) "មានប្រាជ្ញាអាក្រក់" វិ. ទុម្មេធា យស្ស អត្ថី'តិ > ទុម្មេធី (ជនោ); អត្ថិតទ្ធិត ។

រក្ខតិ កិ. (រក្ខ+អ+តិ-រ-) "រក្សា, ថែទាំ,..." ។

សេដ្ឋំវ សន្ធិ. (សេដ្ឋំ+ឥវ) បរសរលោបសន្ធិ ។

អនុយុញ្ជេថ កិ. (អនុ+យុជ+អ+ឯថ-ស.បុ.១.អា.) "គប្បីប្រកប រឿយៗ,..." ។

កាមរតិសន្ថវ បុំ. (កាមរតិ+សន្ថវ) "សេចក្តីស្និទ្ធស្នាលដោយតម្រេក ក្នុងកាម" វិ. កាមរតិយា សន្ថវោ > កាម-រតិសន្ថវោ; ឆដ្ឋី. តប្បុ. ។ កាមរតិ "សេចក្តីត្រេកអរក្នុងកាម" (កាម+រតិ; វិ. កាមេ រតិ > កាមរតិ; ស. តប្បុ. ។

ឈាយន្ត ត្រ. (ឈេ+អ+អន្ត,ឯកៃ'ឈ > អាយ) "កាលដុត, កាល សំឡឹង,..." ។

បប្បោតិ កិ. (ប+អប+ឧ+តិ-រ.) "ដល់ សម្រេច,..." ។

វិបុល នបុំ.,ត្រ. (វិ+បុល+អ) "ច្រើនលើសលុបវិសេស = (ដ៏ធំធេង)" វិ. វិសេសេន បុលតី'តិ > វិបុលំ (ធម្មជាតំ); ក.ក. ។

សុខ នបុំ. (សុ+ខម+ឌ) "(ធម្មជាត) ដែលគេអត់ទ្រាំបាន ដោយងាយ = (សេចក្តីសុខ)" វិ. សុដ្ឋុ ខមិយ-តេ'តិ > សុខំ (ធម្មជាតំ) កម្ម.កម្ម. ។

## ៨– មហាកស្សបត្ថេរវត្ថុ

បមាទំ អប្បមាទេន យទា នុទតិ បណ្ឌិតោ
បញ្ញាបាសាទមារុយ្ហ អសោកោ សោកិនឹ បជំ
បព្វតដ្ឋោវ ភុម្មដ្ឋេ ធីរោ ពាលេ អវេក្ខតិ ។

(ប្រែ) អ្នកប្រាជ្ញបន្ទោបង់នូវសេចក្តីប្រមាទ ដោយសេចក្តីមិនប្រមាទ ក្នុងកាលណា, អ្នកប្រាជ្ញនោះជាអ្នកមិនមានសោករមែងឡើងកាន់ប្រាសាទគឺបញ្ញា ហើយពិចារណាឃើញនូវសត្វ អ្នកមានសោកក្នុងកាលនោះ, អ្នកប្រាជ្ញនោះរមែងពិចារណាឃើញនូវជនពាលទាំងឡាយ ដូចជាបុគ្គលឋិតនៅលើកំពូលភ្នំ ឃើញនូវជនទាំងឡាយ ដែលឋិតនៅលើផែនដីដូច្នោះ ។

### ពន្យល់វេយ្យាករណ៍

បមាទ, អប្បមាទ, បណ្ឌិត ចូលមើលរឿងសាមាវតីលេខ ១ ក្នុងអប្បមាទវគ្គទី ២ ។

យទា — អ.សព្វ. (យ+ទា) "ក្នុងកាលណា" វិ. យស្មឹ កាលេ > យទា ។

នុទតិ — កិ. (នុទ+អ+តិ-វ.) "បន្ទោបង់, ..." ។

បញ្ញាបាសាទមារុយ្ហ — សន្ធិ.(បញ្ញាបាសាទំ+អារុយ្ហ) និគ្គហិតាទេសសន្ធិ ។

បញ្ញាបាសាទ — បុំ. (បញ្ញា+បាសាទ) "ប្រាសាទគឺប្រាជ្ញា"

វិ. បញ្ញាយ បាសាទោ > បញ្ញាបាសាទោ; អវធារណបុព្វបទ ។

អារុយ្ហ អ. (អា+រុហ+ត្វា,ត្វា>យ) "ឡើងហើយ, ជិះហើយ, ពាក់ហើយ" ។

អសោកោ គុ.(ន+សោក) "មានសោកមិនមាន, មិនមានសោក" វិ. នត្ថិ តស្ស សោកោ'តិ > អសោកោ; នបុព្វបទ. ពហុព្វី. ។

សោកិនី ត. (សោក+ឥន)+ឥ-ត.) "មានសោក" វិ. សោកោ យស្សា អត្ថី'តិ > សោកិនី; អត្ថត្ថិត ។

បជា ត. (ប+ជន+ក្វិ) "សត្វ, ពពួកសត្វ" ។

បព្វតដ្ឋោវ សទ្ធិ. (បព្វតដ្ឋោ+ឥវ) បរសរលោបសន្ធិ ។

បព្វតដ្ឋ បុ. (បព្វត+ឋា+អ) "អ្នកឋិតនៅលើភ្នំ" វិ. បព្វតេ តិដ្ឋតី'តិ > បព្វតដ្ឋោ; ត.ក. ។

ភុម្មដ្ឋ បុ. (ភុម្ម+ឋា+អ) "អ្នកឋិតនៅលើផែនដី" វិ. ភុម្មេ តិដ្ឋតី'តិ > ភុម្មដ្ឋោ; ត.ក. ។

ធីរ បុ. ចូរមើលរឿងសមាវតីលេខ ១ ក្នុងអប្បមាទវគ្គទី២ ។

ពាល បុ. ចូលមើលរឿងពាលនក្ខត្តលេខ ៤ ក្នុងអប្បមាទ-វគ្គទី ២ ។

អវេក្ខតិ កិ. (អវ+ឥក្ខ+អ+តិ-ត.) "ក្រឡេកមើល, គន់មើល, ពិចារណាឃើញ" ។

## ៦-ទ្វេសហាយកភិក្ខុវត្ថុ

**អប្បមត្តោ បមត្តេសុ សុត្តេសុ ពហុជាគរោ**
**អពលស្សំវ សីឃស្សោ ហិត្វា យាតិ សុមេធសោ ។**

(ប្រែ) បុគ្គលអ្នកមានប្រាជ្ញាល្អ កាលបើជនទាំងឡាយប្រមាទហើយ លោកជាអ្នកមិនប្រមាទ កាលបើជនទាំងឡាយដេកលក់ហើយ លោកជាអ្នកភ្ញាក់រឭកច្រើន រមែងលះបង់ (នូវជនមានប្រាជ្ញាខ្សោយនោះ) ហើយទៅ. ដូចជាសេះមានសន្ទុះហើសលះបង់នូវសេះមានកម្លាំងថយ ។

### ពន្យល់វេយ្យាករណ៍

អប្បមត្ត, បមត្ត ចូរមើលរឿងសាមាវតីលេខ ១ ក្នុងអប្បមាទវគ្គទី ២ ។

សុត្ត គុ. (សុប+ត) "ដេកលក់ហើយ, កំពុងដេកលក់" ។

ពហុជាគរ គុ. (ពហុ+ជាគរ) "មានសេចក្តីភ្ញាក់រឭកច្រើន"
វិ. ពហុ ជាគរោ យស្ស សោ > ពហុជាគរោ;
ឆ. ពហុព្វី. ។ ជាគរ < ជាគរ+អ; វិ. ជាគរណំ >
ជាគរោ; ភ. ក. ។

អពលស្សំវ សន្ធិ. (អពលស្សំ+ឥវ) បរសរលោបសន្ធិ ។

អពលស្ស បុំ.,គុ. (អពល+អស្ស) "សេះមានកម្លាំងមិនមាន"
វិ. អពលោ អស្សោ > អពលស្សោ; វិ. បុ. ។
អពល < ន+ពល; វិ. នត្ថិ ពលំ ឯតស្សាតិ >
អពលោ (អស្សោ); នបុព្វបទ ឆ. ពហុព្វី. ។

ហិត្វា អ. ( ហា+ត្វា ) "លះបង់ហើយ, ..." ។

យាតិ កិ. ( យា+អ+តិ-វ. ) "ទៅ, ប្រព្រឹត្តទៅ, ..." ។

សុមេធស គុ. ( សុមេធា + ស ) "មានប្រាជ្ញាល្អ" វិ. សុន្ទរា មេធា យស្ស អត្ថីតិ > សុមេធសោ; អត្ថិតទ្ធិត ។

### ៧– មឃវត្ថុ

**អប្បមាទេន មឃវា ទេវានំ សេដ្ឋតំ គតោ**
**អប្បមាទំ បសំសន្តិ បមាទោ គរហិតោ សទា ។**

(ប្រែ) ទេវរាជឈ្មោះមឃវៈ ដល់នូវភាពនៃខ្លួនជាអ្នកប្រសើរដោយវិសេសជាងទេវតាទាំងឡាយ ដោយសេចក្ដីមិនប្រមាទ, បណ្ឌិតទាំងឡាយតែងសរសើរនូវសេចក្ដីមិនប្រមាទ, សេចក្ដីប្រមាទ បណ្ឌិតទាំងឡាយតែងតិះដៀលហើយសព្វ ៗ កាល ។

### ពន្យល់វេយ្យាករណ៍

អប្បមាទេន, បមាទោ ចូរមើលរឿងសម្រាប់លេខ ១ ក្នុងអប្បមាទ-វគ្គទី ២ ។

មឃវា បុំ. ( មឃ+វន្តុ ) "(មាណព) មានឈ្មោះថាមឃ= (ព្រះឥន្ទ)" វិ. មឃោ នាម យស្ស អត្ថីតិ > មឃវា; អត្ថិតទ្ធិត ។

ទេវ បុំ. ( ទិវ+ណ ) "(សត្វវិសេស) អ្នកលេងដោយអារម្មណ៍មាន

បញ្ចកាមគុណជាដើម=(ទេវតា)" វិ. និព្វត្តិ បញ្ច-
កាមគុណានីហិ តាំឡុត្តិតិ>ធេភ ក.ក. ។

សេដ្ឋតា គុ.(សេដ្ឋ+តា) "ភាពនៃខ្លួនជាអ្នកប្រសើរដោយវិសេស" វិ. សេដ្ឋស្ស ភាវោ>សេដ្ឋតា; ភាវតទ្ធិត ។
សេដ្ឋតំ សេដ្ឋតា+អំ ទុតិ.វិ. ។

គតា គុ.(គម+ត) "ទៅហើយ, ដល់ហើយ" ។

បសំសន្តិ ក្រ.(ប+សំស+អ+អន្តិ-វ.) "សរសើរ,..." ។

គរហិតោ គុ.(គរហ+ឥ-អា.+ត) "តិះដៀលហើយ,..." ។

## ៨- អញ្ញតរភិក្ខុវត្ថុ

អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
សញ្ញោជនំ អណុំ ថូលំ ឌហំ អគ្គីវ គច្ឆតិ ។

(ប្រែ) ភិក្ខុអ្នកត្រេកអរក្នុងសេចក្ដីមិនប្រមាទ ឬជាអ្នកឃើញភ័យក្នុងសេចក្ដីប្រមាទ រមែងដុតនូវសំយោជនៈតាំងតូចតាំងធំ, ដូចជាភ្លើងឆេះ (នូវកំញម) ដូច្នោះ ។

### ពន្យល់វេយ្យាករណ៍

អប្បមាទរតោ គុ.(អប្បមាទ+រត) "អ្នកត្រេកអរក្នុងសេចក្ដីមិនប្រមាទ" វិ. អប្បមាទេ រតោ>អប្បមាទរតោ; ស.តប្បុ. ។

ភិក្ខុ បុំ.(ភយ+ឥក្ខ+រូ) "អ្នកមានការឃើញនូវភ័យក្នុង

សំសារជាប្រក្រតី = (ភិក្ខុ)” វិ. សំសារេ ភយំ ឥក្ខិតុំ សីលំ យស្ស សោ> ភិក្ខុ; ស.ត. ។ ឬ<ភិក្ខុ+រូ ; “អ្នកសុំតាមប្រក្រតី” វិ. ភិក្ខនំ សីលេណា'តិ > ភិក្ខុ ; ក.ត. ។

អប្បមាទ,បមាទ ចូរមើលរឿងសាមាវតី លេខ ១ ក្នុងអប្បមាទ-វគ្គទី ២ ។

ភយទស្សី បុំ. ( ភយ+ទិស,ទិសា>ទស្ស+ណី ) “អ្នកឃើញនូវភ័យ, អ្នកមានកិរិយាឃើញនូវភ័យជាប្រក្រតី , អ្នកឃើញនូវភ័យតាមប្រក្រតី” វិ. ភយំ បស្សតី'តិ > ភយ-ទស្សី; ក.ត. ។ ភយំ បស្សិតុំ សីល-មស្សា'តិ > ភយទស្សី; ស.ត. ។

ភយំ បស្សនំ សីលេណា'តិ>ភយទស្សី;ក.ត.។

សញ្ញោជន ទបុំ. ( សំ+យុជ+យុ;ឧ+យ>ញ្ញ,ទ>ន ) “(កិលេសជាត) ជាគ្រឿងប្រកបព្រម (នៃសត្វ) = (សំយោជន-កិលេស) វិ. សំយុជតិ ឯតេនា'តិ> សញ្ញោជនំ (កិលេសជាតំ) ក.ករ ។

អណុំថូល គុ. (អណុ+ថូល) “តូចផងធំផង, តាំងតូចតាំងធំ” វិ. អណុច ថូលំ ច > អណុំថូលំ (សញ្ញោជនំ); ទុ.ឧ-អ.។ វិសេសនោភយបទ ។

ឌហន្ត គុ. ( ទហ,ទហ>ឌហ+អន្ត ) "កាលដុត, កាលឆេះ,..." ។
ឌហំ<ឌហន្ត+សិ,ន្ត+សិ>អំ ។

អគ្គិ បុំ. (អគ្គ+ឥ) "(សភាវ)ដល់នូវកិរិយាកោងកាច=ភ្លើង" ។
វិ. អគ្គតិ ភាវុឌ្ឍំ គច្ឆតីតិ > អគ្គិ; ក.ក. ។

គច្ឆតិ កិ. ( គម+អ+តិ-ក. ) "ទៅ, ដល់,..." ។

អគ្គីវ សន្ធិ (អគ្គិ+ឥវ) បុព្វសរលោបសន្ធិ ទីឃបរទីឃសន្ធិ ។

## ៩- និគមវាសិតិស្សត្ថេរវត្ថុ

អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។

(ប្រែ) ភិក្ខុណាត្រេកអរក្នុងសេចក្តីមិនប្រមាទឬ អ្នកឃើញនូវភ័យក្នុងសេចក្តីប្រមាទ, ភិក្ខុនោះមិនគួរសាបសូន្យ (ចាកគុណធម៌ទាំងឡាយមានវិបស្សនាទីនិងមគ្គផលជាដើម) ក្នុងទីជិតនៃព្រះនិព្វានឡើយ ។

### ពន្យល់វេយ្យាករណ៍

អប្បមាទរតោ, ភិក្ខុ, បមាទេ, ភយទស្សី ចូរមើលរឿងអញ្ញតរភិក្ខុ លេខ ៨ ក្នុងអប្បមាទវគ្គទី ២ ។

អភព្វ គុ. (ន+ភព្វ) "មិនគួរ, អភ័ព្វ" ។

បរិហាន នបុំ. (បរិ+ហា+យុ) "កិរិយាសាបសូន្យ, កិរិយាលះបង់" ។

សន្តិក (សហ+អន្ត+ឥក-សកត្ថ-) "ទីជិត, ទីក្បែរ, ទីកៀក" ។

ចប់អប្បមាទវគ្គទី ២

## ចិត្ត ៈ៣

### ១ - មេ យវត្ថុ

ផន្ទនំ ចបលំ ចិ    ទុរក្ខំ ទុន្និវារយំ
ឧជុំ ករោតិ មេ    ឧសុការោវ តេជនំ ។
វារិជោវ ថលេ ខិ    ឱកមោកតឧព្ភតោ
បរិផន្ទតិទំ ចិត្តំ    មារធេយ្យំ បហាតវេ ។

(ប្រែ) អ្នកប្រាជ្ញ ធ្វើចិត្តដែលញាប់ញ័រយ៉េងយ៉ាងដែលរក្សាបានដោយកម្រ ហាមប្រ បានដោយលំបាក ឲ្យជាចិត្តត្រង់ដូចជាជាងព្រួញ ធ្វើព្រួញដូច្នោះ ។ ចិត្តនេះ ( ដែលបុគ្គលដកឡើងអំពីបញ្ចកាមគុណ ហើយបោ ក្នុងវិបស្សនាកម្មដ្ឋាន ) ដើម្បីលះបង់នូវលំនៅនៃមារ រមែងញា ញ័រ ដូចជាត្រីដែលបុគ្គលស្រង់ឡើងអំពីទីអាល័យគឺទឹក ហើយបោះចោលលើគោកដូច្នោះ ។

#### ពន្យល់វេយ្យាករណ៍

ផន្ទន    គុ. ឬ នបុំ. ( ផន្ទ+យុ ) " កិរិយាញាប់ញ័រ " វិ. ផន្ទិយ(តោ'តិ) ផន្ទនំ ; ក.ក. ។

ចបល    គុ.ឬ នបុំ.(ចប+អល.) " កិរិយាយ៉េងយ៉ាង, កិរិយាកំរើក, កិរិយាមិនតាំងនឹង " វិ. ចបិយ(តោ'តិ) ចបលំ; ក.ក. ។

ចិត្ត នបុំ. ( ចិន្ត+ត ) "( ធម្មជាត ) គិតនូវអារម្មណ៍ = ( ចិត្ត )" វិ. អារម្មណំ ចិន្តេតីតិ> ចិត្តំ ( ធម្មជាតំ ) ក.ក. ។

ទុរក្ខ គុ. ឬ បុំ. ( ទុ+រក្ខ+អ ) "ដែល... រក្សាបានដោយកម្រ" វិ. ទុក្ខេន រក្ខិយតីតិ> ទុរក្ខំ ; ក.កម្ម. ។

ទុន្និវារយ នបុំ. ( ទុ+នំ+វរ+ណ្យ ) " ដែលបុគ្គលគប្បីហាមប្រាម ដោយកម្រ" វិ. ទុក្ខេន និវារិតព្វន្តិ> ទុន្និវារយំ ; ក.ក. ។

ឧជុ គុ. ( អជ+ឧ-អនៃអជ>ឧ ) "( ធម្មជាត ) ប្រព្រឹត្តទៅដោយការៈមិនកោង, – មិនវៀច, = ( ត្រង់ )" វិ. អជតិ អកុដិលភាវេន បវត្តតីតិ> ឧជុ ; ក.ក. ។

ករោតិ កិ. ( ករ+ឱ+តិ-វ. ) " ធ្វើ " ។

មេធាវី បុំ. ( មេធា+វី ) មានប្រាជ្ញា = ( អ្នកប្រាជ្ញ )" វិ. មេធា យស្ស អត្ថីតិ> មេធាវី ; អត្ថតទ្ធិត ។

ឧសុការោវ សន្ធិ. ( ឧសុការោ+ឥវ ) បរស្សរលោបសន្ធិ ។

ឧសុការ បុំ. ( ឧសុ+ករ+ណ ) អ្នកធ្វើនូវកូនសរ = ( ជាងកូនសរ )" វិ. ឧសុំ ករោតីតិ > ឧសុការោ ; ក.ក. ។

តេជន នបុំ. ( តិជ+យុ ) " កូនសរ = ( ព្រួញ )" ។

វារិជ — បុ. ( វារិ+ជន+ក្វិ ) (សត្វ) កើតក្នុងទឹក = (ត្រី)
វិ. វារិម្ហិ ជាយតីតិ > វារិជោ; ក.ក. ។

វារិជោវ — សន្ធិ. ( វារិជោ+ឥវ ) បរសរលោបសន្ធិ ។

ថល — នបុ. (ថល+អ) (ទី) ជាទីបិតទៅ = (ទីគោក)
វិ. ថលតិ តិដ្ឋតិ ឯត្ថាតិ > ថលំ
(ឋានំ); ក. អធិ. ។

វុត្ត — គុ. ( វប+ត ) "គឺ... ព្រោះទៅហើយ,..." ។

ឧទកមោទកាទុត្តោ — សន្ធិ. ( ឧទកមោទកោ+ឧត្តោ ) សរាគមសន្ធិ ។

ឧទកមោទក — នបុ.(ឧទក+ឧទក) "ទឹកនិងទឹក, ទីអាល័យគឺទឹក,
លំនៅគឺទឹក" វិ. ឧទកញ្ច ឧទកញ្ច >
ឧទកមោទកំ; សមាហារទ្វន្ទ. ។ ឧទកំ
ឯវ ឧទកំ > ឧទកមោទកំ; អវធារណ-
បុព្វបទ. ។

ឧទ្ធត — គុ. ( ឧ+ធរ+ត ) "គឺ... លើកឡើងហើយ,
គឺ... ស្រង់ឡើងហើយ" ។

បរិជន្តិទំ — សន្ធិ. ( បរិជន្តិ+ឥទំ ) បរសរលោបសន្ធិ ។

បរិជន្តិ — កិ. ( បរិ+ជន្ត+អ+តិ-វ. ) "ញាប់ញ័រ,... ។

មារធេយ្យ — នបុ. ( មារ+ធេយ្យ ) "ចំណាត់នៃមារ, លំនៅ

នៃមារ" វិ. មារស្ស ជេយ្យំ>មារជេយ្យំ; ធ. កម្ម. ។

បហាតវេ អ. [ប+ហា+តវេ] "ដើម្បីលះបង់,..." ។

### ៤. អញ្ញតរភិក្ខុវត្ថុ

ទុន្និគ្គហស្ស លហុនោ យត្ថកាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ

(ប្រែ) ការទូន្មានចិត្ត, ដែលបុគ្គលសង្កត់សង្កិនបានដោយលំបាក ប្រព្រឹត្តទៅរហ័ស មានកិរិយាធ្លាក់ចុះក្នុងកាមឯណានីមួយជាប្រក្រតី ជាការប្រពៃ; (ព្រោះថា) ចិត្តដែលបុគ្គលទូន្មានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

### ពន្យល់វេយ្យាករណ៍

ទុន្និគ្គហ នបុំ. (ទុ+និ+គហ+អ) "ដែលគេផ្ចញ់ផ្ចាល់បានដោយក្រ, ដែលគេសង្កត់សង្កិនបានដោយលំបាក" វិ. ទុដ្ឋុ ទុក្ខេន និគ្គហិយតីតិ>ទុន្និគ្គហំ (ចិត្តំ); កម្ម. កម្ម. ។

យត្ថកាមនិបាតី [យត្ថកាម + និ + បត + ណី] "មានកិរិយាធ្លាក់ចុះក្នុងអារម្មណ៍ដែលបុគ្គលគប្បីប្រាថ្នាក្នុងទីណាជាប្រក្រតី, មានកិរិយាធ្លាក់ចុះក្នុងកាមឯណានីមួយជាប្រក្រតី; វិ. យត្ថកាមេសុ អារម្មណេសុ

និបតិតុំ សីលមស្សាតិ > យត្ថកាមនិបាតិ;
ឧបុំ. ត្រូវស្រុះស្រៀលជាង; ស.ត. ។

ចិត្ត ឧបុំ. ចូរមើលរឿងមេឃិយត្ថេរលេខ១ ក្នុងចិត្តវគ្គទី ៣ ។

ធមេថ បុំ. (ទម+ថ) "កិរិយាខ្វាន" វិ. ធមថំ > ធមថោ;
ក.ក. ។

សាធុ បុ. (សាធ+ឧ) (គម្ពុ) អ្នកញាំងប្រយោជន៍របស់ខ្លួនផង
ប្រយោជន៍របស់អ្នកដទៃឲ្យសម្រេច"=(ប្រពៃ,ល្អ)"
វិ.សាធេតិ បរត្ថំ សាធេតីតិ>សាធុ (កម្ម);ក.ក. ។

គុត្ត ត្រ. (គុប+ត) "ដែល–ខ្ញុំរក្សាហើយ" ។

សុខាវហ ត្រ. (សុខ+អា+វហ+អ) "អ្នកនាំមកនូវសេចក្ដីសុខ" វិ.
សុខំ អាវហតីតិ > សុខាវហំ (ចិត្តំ);ក.ក. ។

## ៣– ឧក្កណ្ឋិតភិក្ខុវត្ថុ

សុទុទ្ទសំ. សុនិបុណំ យត្ថកាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

(ប្រែ) អ្នកប្រាជ្ញគប្បីរក្សានូវចិត្ត ដែលបុគ្គលឃើញដោយកម្រ ក្រៃពេក ល្អិតបំផុត មានកិរិយាធ្លាក់ចុះក្នុងកាមឯណានីមួយជាប្រក្រតី; (ផ្សេង) ចិត្តដែលបុគ្គលរក្សាហើយ រមែងនាំមកនូវសេចក្ដីសុខ ។

### ពន្យល់វេយ្យាករណ៍

**សុទុទ្ទស** គុ. ( សុ+ទុទ្ទស ) "ដែលបុគ្គលឃើញដោយកម្រក្រៃពេក" វិ. សុដ្ឋុ បរមំ ទុទ្ទសំ > សុទុទ្ទសំ; វិ. បុ. ។

**សុនិបុណ** គុ. ( សុ+និបុណ ) "ដ៏ល្អិតក្រៃពេក, ល្អិតបំផុត" វិ. សុដ្ឋុ បរមំ និបុណំ > សុនិបុណំ; វិ. បុ. ។

**ចិត្ត, យត្ថកាមនិបាតិ, សុខាវហ** ចូរមើលរឿងអញ្ញតរភិក្ខុ លេខ ២ ក្នុងចិត្តវគ្គទី ៣ ។

**រក្ខេថ** កិ. ( រក្ខ+អ+ឯថ-ស. ) " គប្បីរក្សា "... ។

**គុត្ត** គុ. ) គុប+ត ) "ដែលបុគ្គលគ្រប់គ្រងហើយ, ដែលបុគ្គលរក្សាហើយ ។

## ៤- ភាគិនេយ្យសង្ឃរក្ខិតត្ថេរវត្ថុ

ទូរង្គមំ ឯកចរំ អសរីរំ គុហាសយំ
យេ ចិត្តំ សញ្ញមេស្សន្តិ មោក្ខន្តិ មារពន្ធនា ។

(ប្រែ) ជនទាំងឡាយណា សង្រួមនូវចិត្តដែលទៅក្នុងទីឆ្ងាយ ត្រាច់ទៅឯកឯងមិនមានសរីរៈ មានគុហាជាទីអាស្រ័យ, ជនទាំងឡាយនោះ តែងរួចចាកចំណងនៃមារ ។

### ពន្យល់វេយ្យាករណ៍

**ទូរង្គម** គុ. ( ទូរ+គម+ក្វិ ) " អ្នកទៅកាន់អារម្មណ៍ក្នុងទីឆ្ងាយ,

អ្នកទៅក្នុងទីឆ្ងាយ " វិ. ទូរេ អារម្មណំ គច្ឆតីតិ > ទូរង្គមំ (ចិត្តំ); ក.ក. ។

ឯកចរ — គុ. ( ឯក+ចរ+អ ) " ត្រាច់ទៅដោយឯកភាព, ត្រាច់ទៅឯកឯង " វិ. ឯកកោវ ចរតីតិ > ឯកចរំ ( ចិត្តំ ); ក.ក. ។

អសរីរ — គុ. ( ន+សរីរ ) "មានសរីរៈមិនមាន, មិនមានសរីរៈ" វិ. នត្ថិ សរីរមស្សាតិ > អសរីរំ ( ចិត្តំ ); នបុ.ឆ.ពហុព្វី. ។

គុហាសយ — គុ. ( គុហា+អាសយ ) " មានគុហាជាទីទៅអាស្រ័យ " វិ.គុហា អាសយោ យស្ស តំ > គុហាសយំ ( ចិត្តំ ); ឆ. ពហុព្វី. ។

ចិត្ត — ចូរមើលរឿងមេឃិយត្ថេរលេខ ១ ក្នុងចិត្តវគ្គទី ៣ ។

សញ្ញមេស្សន្តិ — កិ. ( សំ+យម, ០ + យមនៃយម > សញ្ញ+អ+ឥ-អា.+អន្តិ-វ. ) " នឹងសង្រួម, នឹងប្រុងប្រយ័ត្ន " ។

មោក្ខន្តិ — កិ. ( មុច+យ, ច+យ > ក្ខ+អន្តិ-វ. ) " រួច, លែង, ..." ។

មារពន្ធន — នបុំ. ( មារ+ពន្ធន ) " ចំណងនៃមារ " វិ. មារស្ស ពន្ធនំ > មារពន្ធនំ; ឆ. តប្បុ. ។

## ៤ – ចិត្តហត្ថត្ថេរវត្ថុ

អនវដ្ឋិតចិត្តស្ស សទ្ធម្មំ អវិជានតោ

បរិប្លវប្បសាទស្ស បញ្ញា ន បរិបូរតិ ។
អនវស្សុតចិត្តស្ស អនន្វាហតចេតសោ
បុញ្ញបាបប្បហីនស្ស នត្ថិ ជាគរតោ ភយំ ។

(ប្រែ) ប្រាជ្ញារមែងមិនបរិបូណ៌ដល់បុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន មិនដឹងច្បាស់នូវព្រះសទ្ធម្ម មានសេចក្ដីជ្រះថ្លាអណ្ដែតទៅ ។ ភ័យរមែងមិនមានដល់បុគ្គលអ្នកមានចិត្តមិនទទឹកដោយរាគៈ មានចិត្តដែលទោសខ្ទាំងខ្ទប់មិនបាន មានបុណ្យនិងបាបលះចោលហើយ ភ្ញាក់រលឹកជានិច្ច ។

### ពន្យល់វេយ្យាករណ៍

**អនវដ្ឋិតចិត្ត** គុ. (អនវដ្ឋិត+ចិត្ត) "មានចិត្តមិនខ្ជាប់ខ្ជួន, មានចិត្តមិនតាំងស៊ប់ហើយ, មានចិត្តមិនដំកល់ចុះហើយ, មានចិត្តមិនតាំងមាំហើយ" វិ. អនវដ្ឋិតំ ចិត្តំ យេន សោ > អនវដ្ឋិតចិត្តោ ; តតិ. ពហុព្វី. ។

**អនវដ្ឋិត** គុ. (ន+អវ+ឋា+ត) "មិនខ្ជាប់ខ្ជួន,..." ។

**សទ្ធម្ម** បុំ. (សន្ត+ធម្ម) "ធម៌ស្ងប់" វិ. សន្តោ ធម្មោ > សទ្ធម្មោ; វិ. បុ. ។ "ធម៌របស់អ្នកស្ងប់, ធម៌របស់សប្បុរស" វិ. សន្តស្ស ធម្មោ > សទ្ធម្មោ; ឆ. តប្បុ. ។

អវិជានន្ត គុ. (ន+វិ+ញា, ញា>ជា+ន+អន្ត) "ការមិនដឹងច្បាស់,..." អវិជានន្តោ<អវិជានន្ត+ស, ន្ត+ស>ន្តោ ។

បរិប្លវប្បសាទ គុ. (បរិប្លវ+បសាទ) "មានសេចក្ដីជ្រះថ្លាអណ្ដែតទៅ,..." វិ. បរិប្លវោ បសាទោ យស្ស (សោ) > បរិប្លវប្បសាទោ; ធ. ពហុព្វី. ។

បញ្ញា គ. (ប+ញា+ក្វិ) "(ធម្មជាតិ) ជាគ្រឿងដែលដឹងដ៏ច្បាស់=(ប្រាជ្ញា)" វិ. បញ្ញាយតេ ឯតាយាតិ > បញ្ញា (ធម្មជាតិ); កម្ម. ករ. ។

បរិបូរតិ កិ. (បរិ+បុរ+អ+តិ-វ.) "ពេញ, តែងពេញ;..." ។

អនវស្សុតចិត្ត គុ. (អនវស្សុត+ចិត្ត) "មានចិត្តមិនទទឹកដោយរាគៈ: មានចិត្តដែលរាគៈមិនទទឹកហើយ, មានចិត្តមិនទទឹកហើយ" វិ. អនវស្សុតំ ចិត្តំ យស្ស (សោ) > អនវស្សុតចិត្តោ; ធ. ពហុព្វី. ។

អនវស្សុត គុ. (ន+អវ+សុ+ត) "មិនទទឹកហើយ,..." ។

អនន្វាហតចេតស គុ. (អនន្វាហត+ចេតស) "មានចិត្តដែលទោសមិនទាន់កំចាត់បង់ហើយ, មានចិត្តដែលទោសមិនបៀតបៀនហើយ, មានចិត្តដែលទោសមិនខ្ទាំងខ្ទប់

រឿយ ៗ ហើយ, មានចិត្តគិតទោសបៀតបៀន ខ្លួនទៅរឿយ ៗ មិនមាន" វិ. អនន្វាហតោ ចេតសោ យស្ស ( សោ ) អនន្វាហត-ចេតសោ; ឆ. ពហុព្វី. ។

អនន្វាហត គុ. ( ន+អនុ+អា+ហន+ត ) "... មិនតាមកំចាត់បង់ហើយ..." ។

បុញ្ញបាបប្បហីន គុ. ( បុញ្ញបាប+បហីន ) "មានបុណ្យនិងបាបលះបង់ហើយ" ។ វិ. បុញ្ញបាបំ បហីនំ យេន ( សោ ) បុញ្ញបាបប្បហីនោ; តតិ. ពហុព្វី. ។ បហីន < ប + ហា, អាទេស ហា > ហី + ត > ន; "លះបង់-ហើយ" ។

នត្ថិ កិ. ( ន+អស+អ+តិ–វ. ) "មិនមាន"

ជាគរតោ គុ. ( ជាគរ+អន្ត ) កាលភ្ញាក់រឭក, កាលបើនឹកខ្លួន;..." ។ ជាគរតោ < ជាគរន្ត + ស, ន្ត + ស > តោ ។

ភយ នបុំ. ( ភី+ណ ) កិរិយាខ្លាច, កិរិយាស្ញើប; វិ. ភាយតីតិ : ភយំ; ក.ក. ។

៦– អារទ្ធវិបស្សកភិក្ខុវត្ថុ

កុម្ភូបមំ កាយមិមំ វិទិត្វា
នគរូបមំ ចិត្តមិទំ ឋបេត្វា

## យោធេថ មារំ បញ្ញាវុធេន
## ជិតញ្ច រក្ខេ អនិវេសនោ សិយា ។

(ប្រែ) បុគ្គលគប្បីដឹងច្បាស់នូវកាយនេះថាដូចជាឆ្នាំង គប្បីបិទនូវចិត្តនេះឲ្យដូចជាបិទទ្វារនគរ គប្បីច្បាំងនឹងមារដោយអាវុធគឺបញ្ញា គប្បីរក្សាទុកនូវជ័យ បច្ចូលឈ្នះហើយ មិនគប្បីជាអ្នកជំពាក់នៅឡើយ ។

### ពន្យល់វេយ្យាករណ៍

កុម្ភូបម គុ. ( កុម្ភ+ឧបម ) "មានឧបមាដោយឆ្នាំង" វិ. កុម្ភេន ឧបមា យស្ស (សោ) កុម្ភូបមោ (កាយោ); គតិ. ភិន្ន. ន. ពហុព្វី. ។ "ឧបមាដោយឆ្នាំង, ប្រៀបដោយឆ្នាំង, ដូចជាឆ្នាំង" វិ. កុម្ភេន ឧបមា> កុម្ភូបមា; គតិ. តប្បុ. ។

កាយមិមំ សន្ធិ. ( កាយំ+ឥមំ ) និគ្គហិតាទេសសន្ធិ

កាយ បុំ. ( កុច្ឆិត+អាយ ) "ការកកើតនៃអាការៈដែលបណ្ឌិតគួរខ្ពើម (កាយ)" វិ. កុច្ឆិតានំ (អាការានំ) អា-(យោ) > កាយោ; ឆ. តប្បុ. ។

វិទិត្វា អ. ( វិទ+តិ-ក+ត្វា ) "ដឹងហើយ, ជ្រាបហើយ,..." ។

នគរូបម គុ. ( នគរ+ឧបម ) "មានឧបមាដោយនគរ" វិ. នគរេន

ឧបមា យស្ស តំ > នគរូបមំ (ចិត្តំ); តត.កម្មធា.
ឆ. ពហុព្វី. ។

នគរ — នប៉ុ. (នគ+រ) "(ទី) មានផ្ទះ" វិ. នគា ប្រាសាទា-ទយោ ឯត្ថ សន្តីតិ > នគរំ (ឋានំ); អត្ថិតទ្ធិត ។ "(ទី) មានផ្ទះកុះករ" (នគរ, ក្រុង) [ន+ឃរ, ឃរ>គរ] វិ. ឃនំ សម្បុណ្ណំ ឃរំ ឯត្ថាតិ > នគរំ (ឋានំ); សត្តមី. ពហុព្វី.

ចិត្តមិទំ — សន្ធិ. [ចិត្តំ+ឥទំ] និគ្គហិតាទេសសន្ធិ ។

ចិត្ត — នប៉ុ. ចូរមើលរឿងមេឃិយលេខ ១ ក្នុងចិត្តវគ្គទី ៣ ។

ឋបេត្វា — អ. (ឋប + ឯ + ត្វា) "ចុះហើយ, បិទហើយ, ខ្ទប់ហើយ" ។

យោធេថ — ក្រ. (យុធ+ណេ+ឯថ-ស.) "គប្បីច្បាំងនឹង,..." ។

មារ — ប៉ុ. (មរ+ណ) "(សភាវៈ) សម្លាប់នូវកុសលធម៌" (មារ) វិ. កុសលធម្មំ មារេតីតិ > មារោ (សភាវោ) ក.ក. ។

បញ្ញាវុធ — ប៉ុ. (បញ្ញា+អាវុធ) "អាវុធគឺបញ្ញា" វិ. បញ្ញា ឯវ អាវុធោ > បញ្ញាវុធោ; អវធារណបុព្វបទ ។

អាវុធ — ប៉ុ. (អា+យុធ> អាវុធ+អ) "គ្រឿងប្រហារ=(អាវុធ)"

ជិតញ្ច — សន្ធិ (ជិតំ+ច) និគ្គហិតាទេសសន្ធិ ។

